**TKI0757**

# សម្ភាសន៍ជាមួយ ឈូក ឃីម ភេទស្រី អាយុ៦៨ឆ្នាំ ត្រូវជាម្ចាស់ប្រវត្តិរូប

## មុខងារៈ នារីពេទ្យ

## សព្វថ្ងៃរស់នៅភូមិត្រពាំងរុន ឃុំរាមអណ្តើក ស្រុកគិរីវង់ ខេត្តតាកែវ

## ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ គ្រី ស៊ុយហៀង

## ០១:៥៤:៣៦

## ៥០ទំព័រ

ហៀង ៖ ...កក្កដា២០១០ ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាៗ ធ្វើការសិក្សាស្រាវជ្រាវ និង ប្រមូលឯកសារ ចងក្រងទាក់ទងនឹងរបបខ្មែរក្រហម ដើម្បីទុកជាប្រវត្តិសាស្ត្រថ្ងៃក្រោយ ក្មេងៗអាចសិក្សាពីរបបនឹង ថាតើវាមានរឿងអីខ្លះកើតឡើងក្នុងរបបនឹង ។ ថ្ងៃនេះ គោល បំណងដែលពួកខ្ញុំមកសម្ភាសន៍មីង ដើម្បីចង់ស៊ើបសួរអំពីបទពិសោធន៍របស់មីង កាលពី ជំនាន់ ហើយដូចជា ថាតើមីងធ្វើការអីខ្លះនៅជំនាន់នឹង ឆ្លងកាត់យ៉ាងម៉េចខ្លះ លំបាកម៉េច ខ្លះៗ ។ សុំឲ្យមីងជួយណែនាំ ។ ជាបឋមសុំអ្នកមីងនិយាយឈ្មោះមីង ថាមីងឈ្មោះអី មីង នៅណា មីងកើតនៅណាសិនណាមីង?

ឃីម ៖ ចា៎ស! កើតនៅ ។

ហៀង ៖ មីងឈ្មោះអីគេ?

ឃីម ៖ ឈូក ឃីម ។

ហៀង ៖ មីងអាយុប៉ុន្មាន?

ឃីម ៖ អាយុ៥៨ឆ្នាំ ។

ហៀង ៖ ចុះស្វាមីមីងឈ្មោះអីដែរ?

ឃីម ៖ នេន ឆែម ។

ហៀង ៖ គាត់អាយុប៉ុន្មាន?

ឃីម ៖ អាយុគាត់ ៦៣-៦៨ឆ្នាំហើយ ។

ហៀង ៖ ហើយមីងមានកូនប៉ុន្មាននាក់ដែរ?

ឃីម ៖ កូន៦នាក់ ។

ហៀង ៖ កូនឈ្មោះអីដែរ?

ទឹម ៖ កូនច្បងឈ្មោះ នេន ស្រីយុត, នេន ម៉ាញ, នេន មឿន, នេន មេន, នេន យេន ។

ហៀង ៖ បងធំជាងគេអាយុប៉ុន្មាន? នេន យ៉េន?

ទឹម ៖ នេន យឹម ។

ហៀង ៖ យឹម?

ទឹម ៖ យឹម ។

ហៀង ៖ កូនពៅ?

ទឹម ៖ ចាស! កូនធំមិញ ។

ហៀង ៖ កូនធំអាយុប្រហែលប៉ុន្មាន?

ទឹម ៖ កូនធំអាយុជាង៣០ កូនបងគេ ។

ហៀង ៖ ស្រី?

ទឹម ៖ កូនប្រុសៗវាទៅរៀននាជាមួយម៉ែ មុនដំបូងមានកូនតែមួយ បើមានកូនច្រើនដូចឥឡូវបោះចោលអស់ហើយ ។

ហៀង ៖ ឥឡូវជម្រាបសួរមីងកាលពីមុនជំនាន់ខ្មែរក្រហម មុន ប៉ុលពត ទៀត មុនឆ្នាំ៧៥ មីងធ្វើអីដែរ?

ទឹម ៖ បាននៅជាមួយ មុនដំបូងនៅកន្លែងអគ្គការស្រុកគេនឹង នៅកាត់ដេរ ។

ហៀង ៖ អីចឹង មីងចូលធ្វើបដិវត្តមុនឆ្នាំនឹងទៀត?

ទឹម ៖ អត់ ចង់ភ្លេច ដូចភ្លេចភ្លាំងអស់ ចាស់ទៅ ។

ហៀង ៖ អត់អីទេមីង ។ មីងនៅចាំទេ ជំនាន់ប៉ុលពតចូល មុនវៃបែកភ្នំពេញ មីងស្នាក់នៅណា?

ទឹម ៖ មុននឹងស្នាក់នៅៗតូចៗ មិនទាន់មាន មិនទាន់ហ៊ានចូល មិនដឹងធ្វើអីទេ កាលនឹងគេហៅធ្វើលើកភ្លឺស្រែលើកអី បេះទៅតាមកងចល័ត ដកស្ទូងអីចឹងទាំងយប់ទាំងថ្ងៃ ។

ហៀង ៖ អីចឹងមុនពេលមីងចូលធ្វើកងចល័តនឹង មុនមានខ្មែរក្រហម មុនកាលនឹងកំពុងជំនាន់លន់នល់អីចឹង នឹងនៅក្រោយនឹងទៀត មីងស្នាក់នៅណា?

ទឹម ៖ ស្នាក់នៅខាងលិចភ្នំ នៅជាមួយម៉ែឪ ។

ហៀង ៖ ភ្នំណាវិញ?

ទឹម ៖ ភ្នំកំពែង ស្រុកគីរីវង់ ។

ហៀង ៖ ភ្នំកំពែង នៅក្នុងណាភូមិ?

ទឹម ៖ ភូមិពន្លៃ ។

ហៀង ៖ ឃុំ?

ទឹម ៖ ឃុំកំពែង ។

ហៀង ៖ អីចឹងមីងស្នាក់នៅនឹងរហូតដល់សម័យខ្មែរក្រហមបានគេ?

ទឹម ៖ បានគេជ្រើសរើស ។

ហៀង ៖ ជ្រើសរើសដល់ណា?

ទឹម ៖ ជ្រើសរើសគេយកទៅធ្វើទ័ព ។

ហៀង ៖ ធ្វើទ័ព! មីងស្រីហ្នឹង?

ទឹម ៖ ស្រី ។

ហៀង ៖ កាលនឹងមីងអាយុប៉ុន្មាន?

ទឹម ៖ អាយុទើបជាងកាលនឹង១៥-១៦-១៧ អត់ទាន់មានចេះស្លៀកសំពតទេ ចេះស្លៀកខោ ។

ហៀង ៖ ពេលគេរើសមីង រើសចេញពីណា?

ទឹម ៖ មុនដំបូងរើសចេញពីតាមភូមិឃុំ ។

ហៀង ៖ ពីណាអ្នករើសមីង?

ទឹម ៖ ភូមិ មេឃុំគេ ។

ហៀង ៖ មេឃុំកំពែងនឹង?

ទឹម ៖ មេឃុំកំពែង ។

ហៀង ៖ ឈ្មោះអីដែរ?

ទឹម ៖ ឈ្មោះតាញ៉េប ។

ហៀង ៖ តាញ៉េប គាត់នៅទេសព្វថ្ងៃ?

ទឹម ៖ តាញ៉េបនឹងយកវ៉ៃចោល ។

ហៀង ៖ វ៉ៃចោលជំនាន់នឹង?

ទឹម ៖ វ៉ៃចោលជំនាន់នឹង គាត់ធ្វើបាបដូចថាដើររំលោភស្រីៗ អង្គការយើងចាប់យកទៅវ៉ៃចោល អត់មានអប់រំទេ យកទៅវ៉ៃចោល ដើរឈ្លានពាននារីនៅក្នុងមន្ទីរនឹង ធ្វើបាបអ្នកណាស្អាតធ្វើបាបរំលោភតាមអំពើចិត្ត ។ ហើយកាលនឹង ខ្ញុំជំនាន់នឹង ខ្ញុំនៅក្មេងៗដល់ពេលនេះអីចឹងយកទៅដាក់ដេកម៉ាកន្លែងអីចឹង គាត់ចេះថាក្មេងៗតូចៗថា ក្មេងខ្លះសំពត់ធ្លាក់នៅចុងជើងខ្លះដឹងស្អី គាត់ដើរចាំងពល់យប់ ហើយយើងក្មេងរពិសៗអត់ដឹងអីនោះ អាសំពត់ស្លៀក

មិនទាន់ដាប់ផង គេហៅមកចូលធ្វើកងទ័ព មានទាន់ចេះស្អី។ ហៅមកធ្វើនឹងអត់សោះ។ ដល់អីចឹងហើយ វាយើងបញ្ជូនមកតាមស្រុកមួយៗចេញពីស្រុកអីចឹង នៅតាមស្រុកតាមភូមិអីចឹង គេឲ្យមកកាត់ដេរ។ ដល់មកកាត់ដេរ អត់មានចេះដែរ ដេរថ្ងៃណាក៏បាក់ ម៉ាម្ជុរ វាអត់មានចេះ ចុះអត់មានហ្វឹកហ្វឺនរៀនកាត់ដេរនឹងអីអត់ចេះសោះ។

ហៀង ៖ អីចឹងមុនពេលដែលមីងចូលគេរើសមីងនឹង មីងអត់ចេះអីទាំងអស់?

ទឹម ៖ អត់ចេះអីទាំងអស់។

ហៀង ៖ ហើយកាលនឹងខាងគណៈឃុំ?

ទឹម ៖ គណៈស្រុកគេរើស។

ហៀង ៖ គណៈស្រុកគេអ្នកមករើសមីង?

ទឹម ៖ អ្នករើសខ្ញុំដេរ។

ហៀង ៖ គណៈស្រុកគេអ្នកមករើសមីង ប៉ុន្តែគេមកប្រាប់ខាងឃុំសិន?

ទឹម ៖ ហ្នឹងហើយ។

ហៀង ៖ គេប្រាប់ឃុំនឹងហើយបាន...តាញ៉ៅបនឹងមកហៅមីង? មកហៅមីងទៅៗដល់ណា?

ទឹម ៖ មក ដំបូងបង្អស់គេឲ្យទៅនៅភ្នំដីរមាល អានឹងទៅធ្វើទ័ព ចេញ។

ហៀង ៖ ឆ្នាំណាដែរ មីងចាំទេ?

ទឹម ៖ អឺ! ភ្លេចអស់ហើយ។

ហៀង ៖ ប៉ុន្តែចូលភ្លាម?

ទឹម ៖ ចូលភ្លាម។

ហៀង ៖ កាលនឹងគេញ៉ាំបាយរួមនៅ?

ទឹម ៖ សហករណ៍។

ហៀង ៖ គេមានសហករណ៍?

ទឹម ៖ មិនទាន់រួមទេ។

ហៀង ៖ អត់ទាន់មានទេ?

ទឹម ៖ ចា៎ស! អត់ទាន់រួមទេ.... កាលនឹងចាំចេះ ពេលដែលគេបោះឡានហោះ គេបោះហើរខ្លាំង គេបោះគ្រាក់ចេញ ដល់នេះគេហៅខ្ញុំចេញទៅៗតាមគេបណ្តោយ។ កាលនឹងទៅនៅតាមភ្នំពេញអត់ទាន់មានបែកទេណា។ អឺចាំៗអត់ទាន់មានបែកមានអត់ទាន់អីទេ នៅស្រុកយើង

មានទាហានតាមអីនឹង អីចឹងគេរើសនារីតូចៗធំអីគេយកទៅហើយ ។ ដល់ពេលឡានហោះទម្លាក់យើងខ្ទាច ។

ហៀង : យន្តហោះ?

ទីម : ហ្នឹងហើយយន្តហោះ ទម្លាក់ អាម៉ិចវាទម្លាក់គ្រាប់នោះ ហើយគេចាប់កំពុងចាប់អ្នកយកការណ៍យកអីនោះគិញអីចឹង ខ្ទាចពេលបបួលគ្នារត់មកវិញ គ្នាជាង៣០នាក់តូចៗ ។

ហៀង : ប្រហែលមីងនៅធ្វើទ័ពនឹង ប្រហែលបានប៉ុន្មាន?

ទីម : ទៅបានតែ៣ថ្ងៃ ។

ហៀង : ៣ថ្ងៃ?

ទីម : ៣ថ្ងៃវាឲ្យយើងហូបនឹង បើហូបទាន់ៗ បើមិនទាន់ដាក់ក្នុងស្លឹកបាយបបរ ។ បបរហើយដែលឈឺនៅក្នុងកន្លែងមន្ទីរនឹង គ្រាន់តែឃើញអាឈឺហើមៗខៀវ សុទ្ធតែចាញ់ ។ ដល់ពេលដែលចាញ់វាមានផាប់ ញាក់ៗផាប់ ហើយពេទ្យអត់មានពេទ្យមានអីទេ ។ ដល់ពេលគេបបរបាយ អត់មានឲ្យហូបបាយត្រឹមត្រូវទេ គេដាក់បបរអីចឹង មានស្លឹកឈើគ្រប់មុខគេឲ្យដើរបេះស្លឹកឈើគ្រប់មុខយកមកបបរហូបទៅ ។ នៅពេលអត់មានចានមានអី អត់មានហូបមានអី មានតែអំបិល ។ ដល់ពេលយើងហូបនឹង ស្លឹកដូង ស្លឹកត្របែកនឹងគេវដូចចានឲ្យយើងយកស្លឹកឈើជួសហូប បើហូបទាន់ក៏ទាន់ បើហូបអត់ទាន់ក៏អត់ដែរ ។

ហៀង : មីងនៅបានតែ៣ថ្ងៃគត់?

ទីម : នៅបានតែ៣ថ្ងៃ អីចឹងនាំគ្នារត់ ។

ហៀង : នាំគ្នាប៉ុន្មាននាក់ដែរ?

ទីម : គ្នា៣៨នាក់ ។

ហៀង : នាំគ្នា៣៨នាក់រត់ពីនឹងមកវិញ?

ទីម : រត់ៗពីកន្លែងគេយកទៅធ្វើទ័ពនឹង ។

ហៀង : ឈ្មោះអីគេម្ដងទៀត?

ទីម : ភ្នំដំរីរមាល ហៅទៅដល់ភ្នំដំរីរមាលនឹងបាន៣ថ្ងៃ ឃើញគេឈឺផាប់ខ្ទាចៗផាប់ដូចគេដែរព្រោះអីដល់ពេលហូបៗគ្មានបានគ្រប់គ្រាន់ទេ ។ គេធ្វើបាបយើងអីចឹង ឲ្យទៅបេះស្លឹកឈើផ្លែឈើពេញតែព្រៃហូប ។

ហៀង : មីងទៅដល់នឹង មីងធ្វើអីគេដែរ ៣ថ្ងៃនឹង?

ទីម : ៣ថ្ងៃនឹង គេយកឲ្យធ្វើទ័ព ។

ហៀង ៖ ធ្វើទ័ពមីងបានធ្វើអីខ្លះ?

ខឹម ៖ អត់ទាន់មានបានធ្វើស្អី គេហៅហាត់ហៅអីខ្លាច ។

ហៀង ៖ អត់បានហាត់ទេ?

ខឹម ៖ ចាស! កាំភ្លើងសុទ្ធតែបំពាក់អាវុធឯងណាកើតអួសដីនឹង ក្មេងតូចៗ ខ្ញុំទៅមិនបានទេកាលនឹង ។

ហៀង ៖ មីងបានកាន់កាំភ្លើង?

ខឹម ៖ អត់ទេ ។

ហៀង ៖ អត់បានកាន់?

ខឹម ៖ អត់បានសោះ ។

ហៀង ៖ ហើយមីងរត់៣៨នាក់នឹង រត់មកនៅណា?

ខឹម ៖ ៣៨នាក់ ដល់នេះទ័ព ដល់ប្រធានគេៗប្រាប់ថា ក្មេងៗនឹងបើសិនណាជារត់គឺគិញ គេវៃចោលណា គេប្រាប់អីចឹងណាគេប្រជុំប្រាប់ថា *"កាលណាប្អូនឯងទាំងអស់គ្នារត់ចេញពីក្នុងមន្ទីរតែរត់ចាប់បានគឺគិញហើយ គឺគិញលន់ នល់ពេញ"*កាលនោះគេថាអីចឹង ។ ដល់អីចឹងយើងទាំងអស់គ្នាអត់រត់យំពេញតែព្រៃ ។ ដល់នេះគេធ្វើច្បាប់ ឲ្យបញ្ជូនមកវិញ នារសាថា *"នារីទាំងអស់គ្នា៣៨នាក់ យកមកដាក់មាត់អន្លង់ម៉ង ពូកែៗរត់ ពូកែលួន"* គេថា *"ដល់ពេលហៅមកៗស្រួលម៉េច ដល់ពេលឲ្យហាត់ពុតចេះរៀនសូត្រក៏មិនទៅតាមគេ"* ។

ហៀង ៖ ពីណាគេអ្នកនិយាយពាក្យនឹង?

ខឹម ៖ ប្រធានគេ ប្រធានកង ។

ហៀង ៖ ប្រធានឈ្មោះអី?

ខឹម ៖ អត់ស្គាល់ ទើបនឹងនៅ៣ថ្ងៃ មិនទាន់អីនឹងស្គាល់ប្រធានគេហៅសំឡុតយើងរហូត ដើមឈើធំៗ ។

ហៀង ៖ គេហៅមកនិយាយកន្លែងណា?

ខឹម ៖ មកហៅប្រជុំនៅដើមឈើធំៗ នៅក្បែរជើងភ្នំវីរមាល ហើយភ្នំនឹងសែនមហាចាញ់ផាប់ ។ ឈើចាញ់ផាប់ច្រើនសុទ្ធហើម ។

ហៀង ៖ ហើយនារសានឹងក៏ធ្វើ?

ខឹម ៖ នារសាគេបណ្ដើរមក គេថាបានដាក់ម៉ាអន្លង់ទាំងអស់ ។

ហៀង ៖ នារសាឈ្មោះអី?

ទឹម :	នារសាម៉េចនឹងចាំ នារសាពួកតំបន់ នារសាកូនក្មេងតូចៗនាំទៅការភ្ជើងគេមួយ ។

ហៀង :	ដូចឈ្លប?

ទឹម :	ឈ្លបគេនឹង នារសានឹងឈ្លប ហើយគេនាំអីចឹងៗដើរកាត់ព្រៃភ្នំ ដើរគ្មានឈប់អីចឹង ដើរនាំ យប់ អត់នាំថ្ងៃ តែថ្ងៃសម្រាកអីចឹងហើយ គ្មានៗឲ្យអីហូបទេ ។

ហៀង :	គេនាំមីងមកវិញមែន នារសានឹង?

ទឹម :	នាំមកវិញ ។

ហៀង :	នាំមកខាងណាវិញ?

ទឹម :	នាំមកដល់ស្រុក ដល់ឃុំវិញ ។

ហៀង :	ស្រុកអី?

ទឹម :	ដល់ឃុំកំពែងនឹងវិញ ។

ហៀង :	មីងនៅចាំគ្នា ៣៨នាក់មានឈ្មោះអីខ្លះ?

ទឹម :	អឺ! លែងស្គាល់អស់ហើយ បែកគ្នាស្រុកនេះស្រុកនោះគ្រប់កន្លែងទាំងអស់ សួរថាម៉ាឃុំ ម៉ាស្រុករើសឃុំនេះ២-៣នាក់ ឃុំនោះ២-៣នាក់ យើងយកចូលគ្នាអត់ស្គាល់គ្នា ។

ហៀង :	ចុះមីងមានចាំឈ្មោះម្នាក់អីក្នុងចំណោម៣៨នឹង?

ទឹម :	ស្គាល់ ។

ហៀង :	ពីណាគេ?

ទឹម :	នៅៗតាយឹង ។

ហៀង :	នៅតាយឹង?

ទឹម :	ចា៎ស!

ហៀង :	ភូមិតាយឹង?

ទឹម :	ភូមិតាយឹង ។

ហៀង :	ឃុំអីគេ?

ទឹម :	ឃុំរាមអណ្ដើក ។

ហៀង :	ឃុំរាមអណ្ដើកដូចគ្នា?

ទឹម :	ចា៎ស!

ហៀង :	គាត់ឈ្មោះអីគេដែរ?

ទឹម :	ឈ្មោះ ទី ។

ហៀង ៖ អីគេទី?

ទឹម ៖ ឪពុក ម៉ម ម៉ម ទី ។

ហៀង ៖ ប្រហែលជា ម៉ម ទី?

ទឹម ៖ ចា៎ស!

ហៀង ៖ អាយុប្រហែលប៉ុន្មាន ឥឡូវ?

ទឹម ៖ អាយុប្អូនខ្ញុំបន្តិច.....។

ហៀង ៖ ហើយពេលមកវិញ មីងធ្វើអី?

ទឹម ៖ គេបញ្ជូនទៅតាមស្រុក គេឲ្យទៅនៅតាមសហករណ៍.... នៅក្បែរព្រំដែនវៀតណាម ។

ហៀង ៖ ធ្វើអីគេ?

ទឹម ៖ ឲ្យទៅស្ទូងដក ចិញ្ចឹមទ័ព ។

ហៀង ៖ មីងនៅនោះប្រហែលប៉ុន្មានឆ្នាំ?

ទឹម ៖ នៅនោះបានប្រហែល២-៣ខែ ។

ហៀង ៖ មីងនៅចាំមីងទៅទេ?

ទឹម ៖ ភ្លេចអស់ហើយ ។

ហៀង ៖ កាលនឹងហូបបាយរួមនៅ មានសហករណ៍មានអី?

ទឹម ៖ សហករណ៍ហូបរួម ។

ហៀង ៖ ពេលនឹងហូបរួម?

ទឹម ៖ ហូបរួម ។

ហៀង ៖ ហូបរួមបានយូរ?

ទឹម ៖ ហូបរួមយូរ ពេលនាំទៅធ្វើទ័ពអានឹង អាពេលទៅធ្វើទៅតាមសហករណ៍ផលិតដូចចិញ្ចឹមទ័ព ឲ្យដកស្ទូងតាមក្បែរព្រំដែន។ ថ្ងៃណាក៏ថ្ងៃវៀតណាមវាឡើងមក គេចទៅ មិនគេចសំរាប់ទៅ ហ្នឹងហើយពេលហ្នឹងពេលកំពុងវ៉ៃខ្លាំងដែរ តាមព្រំដែន ។

ហៀង ៖ ពេលត្រឡប់មកវិញ មីងថានារសានាំមីងមកឃុំកំពែងដែល?

ទឹម ៖ ដល់ត្រឡប់មកវិញគេហៅ មកឃុំៗគេចាត់ចែងទៀតទៅតាមស្រុក ។

ហៀង ៖ មីងនៅឃុំកំពែងបានប៉ុន្មាន បានប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

ទឹម ៖ នៅបានប្រហែលជា គ្មានបានប៉ុន្មានឆ្នាំទេ បានប្រហែល២-៣ខែ បានគេចាត់ចែង ។

ហៀង ៖ បានគេបញ្ជូនទៅ?

ទឹម ៖ ចា៎ស! ហ្នឹងហើយ នៅមិនបានម៉ាខែ ។

ហៀង ៖ ទៅខាងជិតភ្នំដិន?

ទឹម ៖ ហ្នឹងហើយ រកផ្លូវរកម៉ែវិញ គេម៉េចឲ្យមក គេរកវ៉ៃចោល កាលពេលទៅគេយកទៅបាន គេដឹងឈ្មោះយើងហើយ ដូចធ្វើទ័ពអីចឹង ។ ដល់អីចឹងគេឲ្យយើងទៅដកស្នូងនៅព្រំដែនវៀតណាម នៅភ្នំដិនអីចឹង ។ ថ្ងៃណាក៏ថ្ងៃថ្នាងឃើញក្បាលខ្មោច ខ្លាចចង់ងាប់ ។

ហៀង ៖ ហើយមីងទៅជាមួយអ្នកណាគេខ្លះមីងចាំទេ ទៅជាមួយគ្នា៣៨នាក់នឹងវិញ?

ទឹម ៖ អានឹងទៅគ្នា៣៨នាក់នឹងបែកគ្នាហើយ នឹងស្រេចស្រុកៗគេចាត់ចែង ទៅមូលជួបបានខ្លះ ជួបខ្លះអត់នៅជួបអីចឹង ។

ហៀង ៖ ហើយពេលទៅនឹង មីងមានឃើញពីណាគេក្នុងចំណោមគ្នាមីងទៅនឹងដែរ?

ទឹម ៖ ទៅ មានទៅ ។

ហៀង ៖ ពេលមីងទៅដល់នឹង មីងធ្វើការប្រហែល២-៣ខែ?

ទឹម ៖ ២-៣ខែរត់ ។

ហៀង ៖ មីងស្គាល់អ្នកកាន់កាប់កងមីង កងភ្នូរ កងអីរបស់មីង?

ទឹម ៖ កងភ្នូរកងអីនឹង ស្លាប់បាត់គោតគោយអស់ហើយ ស្លាប់អស់ហើយ ។

ហៀង ៖ មីងនៅនឹងប្រហែលបានប៉ុន្មាន មូលហេតុអីបានមីងត្រឡប់មកវិញ?

ទឹម ៖ ត្រឡប់មកវិញព្រោះនៅមិនបាន ពេលដែលយើងត្រឡប់ ។

ហៀង ៖ ទៅដល់ភ្នំដិន?

ទឹម ៖ ភ្នំដិនវាចេះថ្នោងបាញ់ខ្លាំងពេក ថ្នោងបាញ់ទ័ពមិត(រត់) ដល់ពួកខ្ញុំមិត(រត់) ដល់រត់ចេញបាត់អស់អីចឹងទៅ គេមកចាត់ចែងមកនៅកន្លែងស្រុកភូមិឃុំចងជាក្រុងទៀតតាមនឹង គេបញ្ជូនមកវិញ ។

ហៀង ៖ មីងដឹងអ្នកណាគេ បញ្ជូនមីងមកវិញ?

ទឹម ៖ បញ្ជូននឹង អានឹងមេទ័ពគេម៉ង ។

ហៀង ៖ មេទ័ពនឹងឈ្មោះអី ចាំទេ?

ទឹម ៖ ភ្លេចតាៗស្អីទេ តានឹងស្លាប់ហើយ ។

ហៀង ៖ ហើយគាត់បញ្ជូនមីងមក?

ទឹម ៖ បញ្ជូនមកៗ ស្រុកៗគេហៅខម្ទេសនាមយើងយកមកធ្វើការ ហៅមករៀនកាត់ដេរ ។

ហៀង ៖ ឆ្នាំណាមីងចាំ?

ទីម ៖ ភ្លេចអស់ ។

ហៀង ៖ ភ្លេចម៉ង?

ទីម ៖ ចា៎ស!

ហៀង ៖ ភ្លេចឈឹងម៉ង?

ទីម ៖ ភ្លេចឈឹង... ។

ហៀង ៖ ប្រហែលក៏អត់ដឹង?

ទីម ៖ អឺ!

ហៀង ៖ នៅប្រាំង នៅវស្សា នៅច្រូតនៅអី?

ទីម ៖ ហៅមកដល់ពេលឈប់ស្ទូងឈប់ដក ហៅមកកាត់ដេរៗអត់ចេះអត់អី ។

ហៀង ៖ ហៅមកឃុំកំពែងដែល?

ទីម ៖ មកនៅនឹង មកនៅស្រុកនឹងម៉ង ហ្នឹងកន្លែងស្រុក១០៩ គេដាក់ស្រុក១០៩ៗគីរីវង់ ។

ហៀង ៖ មកនៅស្រុកនឹងឬក៏មកឃុំទេ?

ទីម ៖ ហ្នឹងស្រុក ។

ហៀង ៖ មីងមកធ្វើការនៅកន្លែងស្រុក?

ទីម ៖ កន្លែងស្រុកនឹងម៉ង ។

ហៀង ៖ មីងនៅធ្វើការម្តុំណាដែរ?

ទីម ៖ ធ្វើម្តុំភូមិត្រពាំងរុន ។

ហៀង ៖ ពេលគេហៅមីងមក មីងនៅចាំពីណាគេអ្នកហៅមីងឲ្យត្រឡប់មកវិញទេ?

ទីម ៖ ហៅត្រឡប់មកវិញ យាយគណៈស្រុកនឹងម៉ង ហៅឲ្យមកកាត់ដេរ ឈ្មោះយាយខឿន ។

ហៀង ៖ យាយខឿន?

ទីម ៖ ហ្នឹង ។

ហៀង ៖ យាយខឿននឹង គាត់ធ្វើជាអី?

ទីម ៖ គណៈស្រុក ។

ហៀង ៖ គាត់ស្អីគេខឿន?

ទីម ៖ ស្អីខឿនទេ ជីតា ។

ហៀង ៖ គាត់នៅរស់ទេ?

ទីម ៖ ខឿននឹងដឹងម៉េច នៅរស់មិនរស់ គេនៅស្រុកឆ្ងាយ គេនៅស្រុកនោះ ។

ហៀង ៖ គាត់នៅណាវិញ?

ទឹម ៖ នៅស្រុក១០៨ ស្រុក១០៥កាលនឹងគេដាក់១០៥ ។

ហៀង ៖ ១០៥នឹងស្រុកអី?

ទឹម ៖ នៅស្រុកនឹង នៅស្ទឹងបៀតជំរីវមាលដែរនឹង ។

ហៀង ៖ គាត់អ្នកហៅមីងមកដើម្បីជួយធ្វើការងារកាត់ដេរ?

ទឹម ៖ ការងារនៅនឹង កាត់ដេរ ដឹងតែដេរអីចឹងទៅ ។

ហៀង ៖ ហើយហៅមកប៉ុន្មាននាក់ មីងចាំ?

ទឹម ៖ ហៅមកដេរ២នាក់ ។

ហៀង ៖ ហៅតែ២នាក់ ក្នុងនោះមានឈ្មោះមីងមួយ?

ទឹម ៖ ឈ្មោះខ្ញុំមួយ ។

ហៀង ៖ ហើយម្នាក់ទៀត អ្នកណាគេ?

ទឹម ៖ ម្នាក់ទៀតនៅភូមិតាយឹង ។

ហៀង ៖ មីងស្គាល់គាត់ទេ?

ទឹម ៖ ស្គាល់ ។

ហៀង ៖ ឈ្មោះអីគេដែរ?

ទឹម ៖ ឈ្មោះ ម៉ម ទី ។

ហៀង ៖ មិញនឹងហៅត្រឡប់មកវិញនឹង?

ទឹម ៖ ហៅមកវិញ មានឈ្មោះ២នាក់ចូលដេរកន្លែងគាត់នឹង ។

ហៀង ៖ មីងមួយ ហើយនឹងម៉ម ទី មួយ?

ទឹម ៖ ចា៎ស!

ហៀង ៖ មីងដេរបានប៉ុន្មានខែ?

ទឹម ៖ ដេរនៅជាប់ប្រហែលជាងម៉ាឆ្នាំ ។

ហៀង ៖ គេមានបង្រៀន មីងមុនទេ?

ទឹម ៖ អត់មានបង្រៀនអីទេ អត់សោះ ។

ហៀង ៖ ហើយមកដេរម៉ឺង?

ទឹម ៖ ឲ្យដេរម៉ឺង ។

ហៀង ៖ ដេរនឹងម៉ាស៊ីន ហើយដេរនឹងដៃ?

ទឹម ៖ ដេរម៉ាស៊ីនដេរ ។

ហៀង ៖ ដេរអីគេ?

ទឹម ៖ ដេរខោអាវៗតាមសហករណ៍ ខោអាវទ័ព ។

ហៀង ៖ ខោអាវខ្មៅនឹង?

ទឹម ៖ ហ្នឹងហើយខោអាវខ្មៅៗ ខោជើងវែងកាត់ៗរហូត ។

ហៀង ៖ ហើយមីងម៉ាថ្ងៃដេរបានប៉ុន្មាន?

ទឹម ៖ ដេរបានម៉ាថ្ងៃៗ៣ដូចថាកំប្លេរៗ ខោអាវដេរត្រង់ៗ បានជាង១០-២០កំប្លេរ ដេរគ្មានឈប់ គ្រាន់តែនោមមិនបានជុះផង ។ ហើយមានចេះអី ដេរខ្លួនឯង កាត់ខ្លួនឯងមើលឃើញអីចឹង ចេះរៀនតាម ។

ហៀង ៖ មីងមានដែលធ្វើខុសអីទេ ពេលដេរនឹង ធ្វើខុសគេមានស្ដីឲ្យ?

ទឹម ៖ ធ្វើខុសក៏គ្រាន់ថាដេរមិនទាន់នឹងគេ គេស្ដី បើរឿងកាត់ខុសកាត់អីអត់ស្ដី ព្រោះអីយើងអត់ស្ដីទេ ព្រោះអីយើងអ្នកអត់ចេះផង ។

ហៀង ៖ មិញមីងថាដេរខុសគេស្ដីឲ្យ?

ទឹម ៖ គ្រាន់ថា យើងធ្វើមិនទាន់គេស្ដីដែរនឹង ។

ហៀង ៖ គេស្ដីម៉េច?

ទឹម ៖ គេស្ដីឲ្យយើងថា ការងារប៉ុននឹងធ្វើមិនកើតមូលហេតុអីបានធ្វើមិនកើត ការងារប៉ុននឹង ។ ហើយខ្ញុំថាអត់ហ៊ានតគេ តៗដឹងគេយកចេញពីណាទៀត ការងារប៉ុននឹងមិនចេះ ចុះបើអត់ចេះស្អី ចុះខោអាវជិនាន់ប៉ុលពត ។

ហៀង ៖ ពីណាគេអ្នកស្ដីឲ្យមីង?

ទឹម ៖ គណៈស្រុកនឹង ។

ហៀង ៖ ម្នាក់ស្រី យាយខឿននឹង?

ទឹម ៖ ចា៎ស! យាយខឿនស្ដី ការងារយើងប៉ុននឹងម៉េចធ្វើមិនកើត ពួកឯងគ្រប់គ្នា បើយកវ៉ៃចោលៗ បើថាមើលទៅមិនកើត ទុកនៅមិនកើត បើមិនចេះដេរ ។ ហើយរឿងស្អីចេះដេរទៀត ដឹងតែកាត់រហូតៗ មើលពុម្ពខោអាវអីចឹង មានគំនិតអីចឹង រកពូៗកាត់ឲ្យណា ។ ហើយយកមកដេររៀនធ្វើតាមគាត់ទៅ

ហើយយើងមិនយល់ការងារក៏គេវ៉ៃយើងចោលដែរ

ហៀង ៖ ហើយម៉េចទៀត បន្ទាប់ពីនឹង មីងនៅប្រហែលបាន?

ទឹម ៖ ដល់ពេលអីចឹងទៅរត់ ។

ហៀង ៖ មីងអ្នករត់?

ទឹម ៖ ខ្ញុំក៏ចេញពីកន្លែងហ្នឹង ។

ហៀង ៖ ម៉េចបានមីងចេញ?

ទឹម ៖ ចេញពីកន្លែងនឹង ចេញពីកន្លែងនឹង ដល់នេះគណៈស្រុកគេឲ្យយើងចេញ ។

ហៀង ៖ គេហៅចេញ?

ទឹម ៖ ចាស!

ហៀង ៖ យាយខឿននឹង?

ទឹម ៖ យាយខឿននឹងឲ្យទៅនៅកន្លែងពេទ្យៗ ថ្ងៃណាក៏ឈ្លោះគ្នាជាមួយពេទ្យនឹង ពេទ្យគេថាឲ្យខ្ញុំ ថាមុខនាងឯង ដូចមុខអាធៀវគីគេចាប់ដាក់រថក្រោះ ។

ហៀង ៖ ធៀវគី?

ទឹម ៖ ចាស! អាធៀវគី ខ្ញុំថាអីចឹង ខ្ញុំចាំថាយាយនឹងមិនធម្មតាទេ សាហាវណាស់ កសាងខ្ញុំមិនធម្មតា ប្រហែលខ្ញុំខ្លាំងនិយាយអីចឹង ។ ដល់អីចឹងហើយខ្ញុំទៅប្រាប់ប្រធានយាយខឿននឹង ទី១បងឯងមើលចុះ កសាងខ្ញុំសុទ្ធដូចមុខអាធៀវគីគេចាប់បាញ់ចោល ហើយគាត់នឹងគាត់របៀបម៉េចដែរ កសាងខ្ញុំគាត់នឹងក៏ខ្លាំង បើខ្ញុំខ្លាំងក៏គាត់ខ្លាំង ។ ដល់ស្អប់ខ្ញុំអីចឹង ចង់រកតាមដានរកសម្លាប់ខ្ញុំ ។ ដល់អីចឹង គាត់ថាទុកនៅក្នុងកងនារីនឹងក៏នៅមិនបានដែរមិត្តនឹងអីចឹងឲ្យវាទៅនៅតាមសហករណ៍ ទោះម៉េចវាសម្លាប់តាមសហករណ៍ ។ ដល់អីចឹងឲ្យខ្ញុំទៅនៅតាមសហករណ៍ គ្នាខ្ញុំ៦-៧នាក់ ទៅតាមឃុំរាមអណ្តើកនឹងវិញ ។ ទៅគ្នា៦-៧នាក់ហ្នឹង ឃុំគេថានារីអស់នឹងតិចខ្លាំងចូលមកវៃសាប់ អត់បបួលគ្នាយាមម្តងម្នាក់ ។ មិនដឹងយាមស្អី គេឲ្យយាមក្រណាត់មកកាត់ដេរវិញទៅ ។ កាត់ដេរដល់នេះ ខ្ញុំអត់បានដេរ ខ្ញុំហៅបេដ្ឋាអាពតនឹងបណ្តោយរាប់រយគូៗក៏គាត់នឹងធ្វើប្រធានភូមិ គាត់ក៏មិនមែនបានស្មើយើង ខ្ញុំក៏អត់ដឹងគេហៅបេដ្ឋា គ្នាអត់ដឹងដែរ ។ ទៅដល់គេហៅបេដ្ឋាតែម្តង ។

ហៀង ៖ នៅណាដែលមីង ភូមិឃុំណា?

ទឹម ៖ ឃុំរាមអណ្តើក ។

ហៀង ៖ ពេលដែលយាយខឿននឹងហៅឲ្យមីងចេញពីកន្លែងកាត់ដេរ មីងនៅកន្លែងកាត់ដេរបានប៉ុន្មានខែ?

ទឹម ៖ ម៉ាឆ្នាំ ។

ហៀង ៖ អីចឹងគេហៅមីងឲ្យនៅកន្លែងពេទ្យវិញ?

ខឹម ៖ ពេទ្យ ។

ហៀង ៖ នៅពេទ្យបានប៉ុន្មានខែដែរ?

ខឹម ៖ ពេទ្យនឹងរៀនមិនទាន់បានប្រហែល១-២ខែស្រួលផង ។

ហៀង ៖ ពេទ្យអី?

ខឹម ៖ ពេទ្យឆ្មប ។

ហៀង ៖ ពេទ្យឆ្មបនៅណា?

ខឹម ៖ ពេទ្យឆ្មបនៅវត្តរាមអណ្ដើក នៅឃុំរាមអណ្ដើក ។

ហៀង ៖ វត្តរាមអណ្ដើក?

ខឹម ៖ ឃុំរាមអណ្ដើក ។

ហៀង ៖ វត្តនឹងឈ្មោះអីគេ?

ខឹម ៖ វត្តមង្គលយូវង្ស ។

ហៀង ៖ ពេទ្យនៅក្នុងវត្ត?

ខឹម ៖ ពេទ្យនៅក្នុងវត្តចុះមានលោកអ្នកណានៅ ។

ហៀង ៖ ពេទ្យនៅក្នុងវត្តនឹងម៉ង?

ខឹម ៖ នៅពេទ្យនៅក្នុងវត្ត គាត់នឹងគាត់ប្រធានធ្វើបាបកូនចៅ គាត់ថាពួកពេទ្យនឹងអីចឹង កាលណាពេលហូបចុកបុកទំពាហូបចុក គាត់ធ្វើបាបយើងអ្នកដែលមិនណែនាំមិនតាមគាត់នោះ គាត់ធ្វើបាបយើងឲ្យហូបបបរទឹកៗជាមួយអ្នកដែលពោះធំ កូនង៉ែតនឹងហូបទឹកៗ ។ ហើយដល់ពេលវេណខ្ញុំ ខ្ញុំនឹកឃើញអាណិតអ្នកឆ្លងទន្លេ ខ្ញុំថាអ៊ីៗទាំងអស់គ្នាបើគេថាម៉េចៗជួយខ្ញុំផង ខ្ញុំជួយឲ្យហូបបបររៀងគោកទឹកបន្តិច ។ ហើយដល់យាយឯងហូបកុំឲ្យឃើញ ហូបកាកឲ្យអស់រៀងនៅទឹកបន្តិច ។ ហូបដល់នៅសល់ទឹកៗ មានខ្លះមានគោក "នារីឯងនិយាយឲ្យស្ដាប់ទេ ខ្លាំងបន្តប់នៅក្នុងកន្លែងនឹងមួយហើយ ឲ្យអ៊ីៗហូបគោកនឹង" ខ្ញុំថា "អ៊ីៗពេទ្យទាំងអស់គ្នា បើសិនណាយាយនឹងតាមដានខ្ញុំ ជួយខ្ញុំផង ពេលឃើញគេមកហូបឲ្យមានរៀងទឹកហូបកាក់អស់ទៅណា កុំថាខ្ញុំៗលើកក្រោយបបរទឹកឲ្យហូបអីចឹងវិញដែរហើយ តែមិនអាណិតខ្ញុំ ។ អ៊ីៗទាំងអស់ពោះធំទាំងអស់គេថា "ពេទ្យអស់រលីងមាននិស្ស័យ អាណិតមានតែឯងទេ" ពេលគាត់ឈឺថ្កាត់អី ខ្ញុំចេះដើរលួចថ្នាំមកលេបហើយ យប់ៗឡើងគាត់ឈឺណាគេអត់ឲ្យហូបទេណា ខ្ញុំដើរលួច ។ ដល់ពេលឲ្យហូបអីចឹងទៅឆ្អែត ព្រោះថាចំណីសហករណ៍

វាមិនឲ្យក្នុងភូមិៗ គេយកមកឲ្យហូបនៅកន្លែងពេទ្យនឹង ប្រធាននឹងដូចថាមានចំណីស្អីសហ-ករណ៍ឲ្យមានបន្លែមមានអីចឹង ហូបមានពោតមានអីអន្ទរអីឆ្ងាញ់ៗ គេស៊ីតែគ្នាគេ ប្រធាននឹង គេអត់ឲ្យយើងស៊ីទេ សុខចិត្តស៊ីសល់ គេយកចាក់ចោលនឹងគុម្ពឫស្សីនឹង ។ ហើយខ្ញុំថា "អ៊ីឯងលើកទីមួយធ្វើបាបសហករណ៍ ចាំដល់ពេលប្រជុំ ប្រាប់គណៈស្រុក កសាងដូចគ្នា យាយឯងចេះស្ដាប់មិនរួចដូចគ្នា ។ យាយឯងធ្វើបាបខ្ញុំៗធ្វើបាបយាយឯង" ដល់ខឹងខ្ញុំតាមដានគាត់ គាត់ទម្លាក់ខ្ញុំថា "ទោះបីម៉េចមួយៗក៏យកនាងនឹងឲ្យទៅនៅតាមភូមិឃុំវិញទៅ" ។ កាលណាតាមភូមិឲ្យវាយកម៉េចសម្លាប់តាមគ្នាតាមភូមិ" និយាយអីចឹងតាមដានខ្ញុំរកវៃចោល ។

ហៀង : មីងនៅក្នុងពេទ្យនឹងជិត២ខែ?

ខឹម : ចា៎ស! នៅបានប៉ុននឹង ។

ហៀង : មីងនៅក្នុងនឹងអំឡុងពេលពី១ទៅ២ថ្ងៃ មីងស្នាក់នៅណាដែរ ហើយមីងឃើញសភាពការណ៍អីគេខ្លះ? មានអ្នកជម្ងឺម៉េចខ្លះ? ហើយថ្នាំពេទ្យម៉េចដែរទៅ?

ខឹម : ថ្នាំពេទ្យ ថ្នាំដំឡូងមីស្អីយើងចាក់ថ្នាំអីធម្មតា សារ៉ូនឹង ថ្នាំនឹងគេបន្ទប់នៅកន្លែងមន្ទីរពេទ្យគេធ្វើអីចឹង គឺនីនស្អីគេចំហ៊ុយយកមកចាក់ ។ ហើយយើងដឹងថាចាក់ឲ្យគេ តែអាប់សែយើងទទួលខុសត្រូវទៀត ។

ហៀង : អាប់សែនឹងអីគេ?

ខឹម : ចាក់ទៅអាប់សែ ហើមខ្ទុះឈឺ តែបូមគ្នាអានឹងធ្វើវេទនាជនាន់នឹង ។

ហៀង : មីងមានគេរីករីនមីង គេបង្ហាត់មីងសិនទេ បានគេឲ្យធ្វើការ?

ខឹម : អត់មានបង្ហាត់ពុតអីសោះ ចាប់យកឲ្យទៅរៀន ។

ហៀង : ម៉ា៉ថ្ងៃអត់ដែរ?

ខឹម : ចា៎ស! អត់សោះ ចាប់យកយើងធ្វើខ្លាំងទាំងដុលធ្វើកើតមិនកើត គេសំឡុតយើងរហូត ។

ហៀង : មីងមានសួរគេថា ពេលមីងមកចូលធ្វើការក្នុងពេទ្យនឹងភ្លាម មីងមានសួរគេថា ខ្ញុំអត់ចេះអីផង ហើយឲ្យខ្ញុំធ្វើការម៉េចទៅ?

ខឹម : គេអត់មានសួរយើងអីចឹងទេ ដឹងតែឲ្យយើងធ្វើតាមគេទៅ គេឲ្យយើងចាក់ថ្នាំចាក់នឹងគេមើលគេ ។

ហៀង : គេមានប្រាប់មើលឲ្យរើសថ្នាំ?

ទីម ៖ តែខ្ញុំចាក់ ខ្ញុំញាក់ណាស់ ខ្ញុំភ័យខ្ញុំស្ទុត ថីមិនស្ទុតបើមិនចេះសោះ ម្ហូវវ៉ែងអីចឹង ចាក់ជ្រុច សុទ្ធតែសំលៀងនឹង ។

ហៀង ៖ សំលៀង?

ទីម ៖ សំលៀងថ្ម មានកូនថ្មគេមួយសំលៀងឲ្យមុតទៅ លាងទឹកយើងបូមៗហើយ យើងយកមក ចំហ៊ុយ ពេលយកមកចាក់ ហើយសុទ្ធតែអាប់សែ ដួនកាលច្រើនអាប់សែណាស់ ។

ហៀង ៖ ម្ហូវៗគេប្រើថ្នាំអី ថ្នាំបរទេស?

ទីម ៖ អត់មានថ្នាំបរទេសទេ ថ្នាំចំហ៊ុយធ្វើចាក់នៅកន្លែងនឹងម៉ង ។

ហៀង ៖ ថ្នាំម៉េច? ថ្នាំអ៊ីគេខ្លះ មីងចាំទេ?

ទីម ៖ ថ្នាំឫសឈើ ឫសអីយកទៅចំហ៊ុយ ។

ហៀង ៖ ថ្នាំឫសឈើម៉េចទៅ?

ទីម ៖ ឫសឈើៗនៅនឹងភ្នំដើមស្អីៗ យកទៅស្ងយកទៅធ្វើស្អីលាយគ្នាអញ្ចឹងណា៎ ដល់ពេលគេ យកចំហុយជាតិញើសហ្នឹងថ្នាំហ្នឹងគេយកទៅលាយមេគេ ។

ហៀង ៖ អញ្ចឹងមែនថ្នាំបរទេសទេ?

ទីម ៖ អត់មានថ្នាំបរទេសណាទេ មកចាក់យើងហ្នឹងអត់មានសោះ ។

ហៀង ៖ មីងមានដែលឃើញគេធ្វើថ្នាំហ្នឹងទេ?

ទីម ៖ ឃើញធ្វើថ្នាំចំហុយយកជាតិញើស ជាតិចំហុយ យកថ្នាំមកចាក់ ហើយអាថ្នាំគ្រាប់ហ្នឹងគឺ ដំឡូងមីយើងហ្នឹង គេយកម្សៅយកទៅបុកលាយឲ្យយើងលេបហ្នឹង ហើយលេបទៅក៏គ្មាន ឃើញស្អីផង ដែលគេហៅថាថ្នាំអាចម៍ទន្សាយហ្នឹង ។

ហៀង ៖ អញ្ចឹងមានដែលឃើញគេធ្វើថ្នាំអាចម៍ទន្សាយហ្នឹងទេ?

ទីម ៖ ឃើញធ្វើ ម្សៅហ្នឹងលាយ ។

ហៀង ៖ មីងធ្លាប់ធ្វើខ្លួនឯងទេ?

ទីម ៖ ខ្ញុំឃើញគេលាយហើយយកមកឲ្យហូបហ្នឹង ។

ហៀង ៖ អញ្ចឹង?

ទីម ៖ ហើយសុំគេមិនឲយទេ គឺតឹងតែងណាស់ ដូចថាយើងអញ្ចឹងណា៎ ឈឺស្អីក្តៅរងាគេថា យើងខ្ជិល ។

ហៀង ៖ មីងមានឆ្ងល់ទេ ហើយមានដែលសួរគេទេថាឈឺអីបានជាដាក់ថ្នាំហ្នឹង ហើយថ្នាំហ្នឹងមាន ព្យាបាលជម្ងឺអីខ្លះទៅ?

ទឹម ៖ ឈឺជម្ងឺរាល់ថ្ងៃ ដួនកាលក្ដៅរង័រ ហើយសុំគេហ្នឹងដួនកាលគេឲ្យហើយដួនកាលគេមិនឲ្យទេ ហើយឲ្យលេខ៤-១០គ្រាប់គ្មានដឹងស្អីណាទេ តែចេះតែលេបទៅ ហើយហ៊ានថាថ្នាំហ្នឹងបរិសុទ្ធគេចាប់យកទៅវ៉ៃចោលហ្នឹង ។

ហៀង ៖ មឹងធ្លាប់ឃើញ?

ទឹម ៖ អារឿងវ៉ៃចោលហ្នឹងចេះតែដំឡាគេទៅ ស្រែកថាគិចខ្ញាំងបន្ទប់នៅក្នុងកន្លែងហ្នឹងមួយអត់និយាយរឿងអីថាថ្នាំគេពិតប្រាកដអញ្ចឹងណា៎ អាណាដឹងថាថ្នាំគេអាចម៍ទន្សាយ ដំឡូងមីអីពិតប្រាកដហ្នឹងរឿងទៀត ។

ហៀង ៖ អញ្ចឹងគេយកដំឡូងមីយកទៅបុក?

ទឹម ៖ គេយកទៅបុកហើយលាយទៅ ។

ហៀង ៖ លាយជាមួយអីមឹង?

ទឹម ៖ លាយជាមួយថ្នាំគេ ថ្នាំទឹកហ្នឹងយកមកចំហុយហើយលាយទៅ ។

ហៀង ៖ អាថ្នាំទឹកគេចំហុយហើយយកមកលាយទៅ?

ទឹម ៖ ហ្នឹងអើយ ។

ហៀង ៖ លាយហើយមូលវាទៅ?

ទឹម ៖ ចា៎!

ហៀង ៖ ពណ៌អីមឹង?

ទឹម ៖ សស្គុស ហុយៗ គេមានពុម្ពគេធ្វើ ។

ហៀង ៖ អ៊ំ! មានពុម្ពទៀត?

ទឹម ៖ មានពុម្ពធ្វើដាក់សង្កត់ដូចគ្រាប់កាំភ្លើងតូចៗ គេមានចុងមួយយកមកសង្កត់ហ្នឹងមូលហើយ ហើយដល់ពេលហើយគេហាលថ្ងៃហើយយកមកឲ្យលេបបន្តិចមើល ។

ហៀង ៖ ហើយចុះមានអ្នកជម្ងឺស្លាប់នៅក្នុងមន្ទីរពេទ្យហ្នឹងទេ ហើយមានច្រើនទេ?

ទឹម ៖ ក្នុងពេទ្យហ្នឹងអត់មានអ្នកជម្ងឺស្លាប់ទេ គ្រាន់តែថាវេទនា ហូបកើតមានតែបបរ ព្រលិតត្រកួន ។

ហៀង ៖ ពីណាគេអ្នករ៉ាប់រងខាងអាហារហ្នឹងមឹង?

ទឹម ៖ ដូចថាពេទ្យហ្នឹងមួយក្រុមគ្នា១០នាក់អញ្ចឹងចែកវេនគ្នាទៅ មួយវេនគ្នា៣នាក់ ម្នាក់ម្ដងៗអញ្ចឹងទៅ ។

ហៀង ៖ អញ្ចឹងពេទ្យហ្នឹងជាអ្នកធ្វើម្ហូបឲ្យអ្នកជម្ងឺញុំ?

ទឹម ៖ ចា៎! ហើយដល់ពេលប្រធានមានបាយមានម្ហូបគេត្រឹមត្រូវ ហើយយើងបុគ្គលិកតូចៗហ្នឹង ស៊ីវេទនាជាមួយគ្នាទៅ ។

ហៀង ៖ ប្រធានហ្នឹងពីណាគេមីង?

ទឹម ៖ ឈ្មោះគេ យាយរឿន ។

ហៀង ៖ គាត់នៅរស់ទេ?

ទឹម ៖ យាយរឿន ហ្នឹងមិតបែកគ្នាអាគាត់អាគាយកាលជំនាន់ ប៉ុល ពត ហ្នឹងហើយឡើងភ្នំ ហ្នឹង ។

ហៀង ៖ ហើយចុះគ្នាមីង មីងមានចាំទេមានប៉ុន្មាននាក់ អ្នកដែលធ្វើការនៅពេទ្យហ្នឹង?

ទឹម ៖ អ្នកនៅពេទ្យហ្នឹងស្លាប់អស់ហើយ ។

ហៀង ៖ ស្លាប់អស់ហើយ?

ទឹម ៖ ចា៎! ព្រោះឈឺ ។

ហៀង ៖ អញ្ចឹងនៅក្នុងពេទ្យហ្នឹងតួនាទីរបស់មីងធ្វើអីដែរ កាលពីជំនាន់នៅក្នុងពេទ្យហ្នឹង?

ទឹម ៖ គ្មានស្អីទេ គ្រាន់តែថាឲ្យចេះតែដាំបាយ ឲ្យចាក់ថ្នាំហ្នឹងតែងតែញាក់ភ័យអត់មានដែលបាន ធ្វើស្អីចេះមួយទេ ។

ហៀង ៖ ហើយថ្នាំពេទ្យអីហ្នឹងក៏អត់មានដែលបានធ្វើដែរ?

ទឹម ៖ អត់ដែលទេ ។

ហៀង ៖ ព្រោះមីងអត់មានបានរៀនពីមុនមក?

ទឹម ៖ អត់មានបានរៀនសោះ ។

ហៀង ៖ អញ្ចឹងនៅក្នុងពេទ្យហ្នឹងអំឡុងពេល២ខែដែលមីងស្នាក់នៅហ្នឹង មីងមានបានឃើញទិដ្ឋភាពអី ខ្លះទៅ?

ទឹម ៖ ឃើញអ៊ីហ្នឹងគាត់វេទនាហួប ហើយគាត់ចេះតែថា ឯងអើយ! កុំតែបានឯងឲ្យស៊ីឲ្យឆ្អែត ឆ្ងាញ់ ខ្ញុំពេលថ្ងៃល្ងាចទៅខ្នុរទុំជុំវិញវត្តហ្នឹង ចេះតែថាអ៊ីៗហួបឲ្យឆ្អែតទៅ ពេលធំទៅអ៊ីឯង ជួយខ្ញុំផង ហើយបើពេលប្រធានគេសួរខ្នុរទុំពេញដើមទៅណាអស់ អ៊ីឯងឆ្លើយខ្ញុំអ្នកឡើង កុំថាខ្ញុំបេះណា៎ ឆ្លើយថាស្អុយទាំងអស់ទៅ ហើយវាទុំជ្រុះ ហើយខ្ញុំបេះឲ្យគាត់ហួបទាល់ តែឆ្អែត ហើយគាត់អួតទាល់តែសព្វថ្ងៃហ្នឹង ។

ហៀង ៖ អញ្ចឹងគាត់នៅរស់ទេ?

ទឹម ៖ នៅរស់ ។

ហៀង ៖ នៅណាដែរអ៊ីហ្នឹង?

ទឹម ៖ នៅរាមអណ្ដើក គាត់នៅតែអួតថាខ្ញុំហ្នឹងចិត្តបាន ហើយនារីពេទ្យស្រីៗហ្នឹងសុទ្ធតែចិត្តអាក្រក់ មានតែឯងមួយទេដែលចិត្តល្អ ដល់ហើយខ្ញុំថាអ៊ីឯងម៉េចៗកុំបន្ទោសខ្ញុំណា បើមិនអញ្ចឹងទេគេវៃខ្ញុំចោលហើយ គ្រូតែអាណិតខ្ញុំ ខ្ញុំមានតែជួយអ៊ីព្រោះឃើញហើមអញ្ចឹង ហើយខ្ញុំថាអ៊ីឯងជួយខ្ញុំទៅខ្ញុំឲ្យអ៊ីឯងហូបឲ្យឆ្អែត ខ្ទះធំ២-៣ ហើយខ្ញុំថាយល់ល្អឆ្លើយថាស្អុយទៅណា ។

ហៀង ៖ គាត់ឈ្មោះអីដែរ មីងមានចាំទេ?

ទឹម ៖ គាត់ឈ្មោះ យាយសេ នៅភូមិរាមអណ្ដើក ។

ហៀង ៖ គាត់អាយុប្រហែលប៉ុន្មានដែរ?

ទឹម ៖ មិនដឹងប៉ុន្មានទេ តែគាត់បងខ្ញុំទៀត ។

ហៀង ៖ ហើយមានអ្នកណាផ្សេងទៀតទេ?

ទឹម ៖ មាន២-៣នាក់ទៀតនោះ ។

ហៀង ៖ ឈ្មោះអីដែរមីង?

ទឹម ៖ ឈ្មោះ អ៊ីស្រ៊ុន ។

ហៀង ៖ អាយុប៉ុន្មានដែរ?

ទឹម ៖ ស្រ៊ុន ហ្នឹងអាយុប្រហែលជា៥០-៦០ហ្នឹង ព្រោះអីគាត់ចាស់ហើយ ហើយខ្ញុំនៅក្មេងហ្នឹង ។

ហៀង ៖ ហើយម្នាក់ទៀតពីណាគេ?

ទឹម ៖ អ៊ី អាន់ ។

ហៀង ៖ គាត់នៅរាមអណ្ដើកទាំងអស់គ្នា?

ទឹម ៖ នៅឃុំរាមអណ្ដើកទាំងអស់ ម៉ាជួរហ្នឹងទាំងអស់ ហើយគាត់មាននិស្ស័យជាមួយខ្ញុំ អាណិតមកដល់សព្វថ្ងៃ ហើយថាឲ្យតែឃើញមុខមីហ្នឹងអាណិតវាណាស់ កាលជំនាន់ ប៉ុល ពត បានស្ពឺមួយម៉ាត់មួយកក៏ប្រាប់យើងដែរ វាចេះលួចគំនិតលាក់ឲ្យយើងហូបដែរ ។

ហៀង ៖ ហើយម៉េញមីងនិយាយថា យាយសេ យាយសេ ហ្នឹងប្ដីគាត់ឈ្មោះអីដែរមីងមានចាំទេ?

ទឹម ៖ ឈ្មោះតាអីទេ ភ្លេចបាត់ហើយ ។

ហៀង ៖ គាត់ធ្វើការអីដែរមីងមានចាំទេ កាលជំនាន់ខ្មែរក្រហម?

ទីម ៖ កាលជំនាន់ខ្មែរក្រហមគាត់អត់មានធ្វើស្អីទេ គាត់នៅតាមសហករណ៍ ហើយប្រពន្ធពោះធំគេឲ្យទៅស្នាក់ពេទ្យអញ្ចឹងណា៎ ពេលជិតកើតអញ្ចឹងគេឲ្យកើតនៅពេទ្យនោះ ។

ហៀង ៖ ហើយមីងនៅក្នុងមន្ទីរពេទ្យហ្នឹង មីងមានគ្នាប្រហែលប៉ុន្មាននាក់ទៅ ទាំងប្រធានទៀត?

ទីម ៖ មានគ្នាជាង១០នាក់ ។

ហៀង ៖ អាហ្នឹងទាំងប្រធានមែន?

ទីម ៖ចា៎!

ហៀង ៖ មីងមាននៅចាំឈ្មោះអ្នកទាំង១០នាក់ហ្នឹងទេ?

ទីម ៖ ភ្លេចអស់ហើយ បែកគ្នាអស់ហើយ អាខ្លះស្លាប់អស់ហើយ នៅចាំបន្ទាប់ប្រធាន អនុប្រធានហ្នឹង នៅស្រុកពេជ្រសារនេះមួយ តែអាហ្នឹងឥលូវគេចេះពេទ្យពិតប្រាកដណា៎ ឈ្មោះ ស្រ៊ា ។

ហៀង ៖ នៅភូមិណាដែរមីង?

ទីម ៖ នៅភូមិមាត់ស្ពាយ ។

ហៀង ៖ ហើយឃុំអីគេ?

ទីម ៖ ឃុំអង្គប្រាសាទ អាហ្នឹងគេបន្ទាប់អនុប្រធានគេធ្វើបាបយើងសមាជិកតូចៗហ្នឹង គេយកទៅដាក់ខ្នោះនៅវត្តអង្គរលាម នាងហ្នឹងក៏ធ្វើបាបដែរ ។

ហៀង ៖ អ្នកណាគេធ្វើបាបមីង?

ទីម ៖ ស្រ៊ា ហ្នឹងក៏ធ្វើបាបសមាជិកតូចៗហ្នឹងដែរ គេបន្ទាប់ប្រធានគេអាងរាយការណ៍ ។

ហៀង ៖ ស្រ៊ា ហ្នឹងអនុប្រធានមែន?

ទីម ៖ ចា៎!

ហៀង ៖ ហើយបាន យាយរឿន?

ទីម ៖ ហ្នឹងអើយ ។

ហៀង ៖ អនុប្រធានមានប៉ុន្មាននាក់?

ទីម ៖ សាខាគេមាន៣នាក់ ។

ហៀង ៖ ៣នាក់ហ្នឹងឈ្មោះអីគេខ្លះមីង?

ទីម ៖ ឈ្មោះ ភឿន ។

ហៀង ៖ គាត់នៅណាមីង?

ទឹម ៖ ភឿន ហ្នឹងក៏ចេញដូចគ្នាដែរ នៅស្រុក១០៥ គេថាក្បាលរឹងគេឲ្យចេញដូចតែគ្នាហ្នឹង អាណាមិនចេះហើយរឹងគេប្រើមិនបានហ្នឹងចេញហើយ កុំឲ្យគេវ៉ៃចោល ។

ហៀង ៖ មីងថាឈ្មោះ ស្រ៊ា ម៉េញនៅភូមិអីគេដែរមីង?

ទឹម ៖ នៅភូមិមាត់ស្វាយ ។

ហៀង ៖ ឥលូវគាត់នៅទេ?

ទឹម ៖ ឥលូវនៅតើ ។

ហៀង ៖ មីងស្គាល់គាត់ទេ?

ទឹម ៖ ធ្លាប់ស្គាល់ គេចេះ តែគេចេះគេធ្វើបាបយើងអាតូចៗហ្នឹងអើយ ។

ហៀង ៖ មីងឮមីងកាលមីងនៅពេទ្យហ្នឹងអាសារឈ្លោះគ្នា?

ទឹម ៖ អាសារឈ្លោះ តែបើឈ្លោះគេតាមដានខ្ញុំ គេខឹងខ្ញុំ យកទៅឲ្យសហករណ៍ញហូបបាយ រាងគោកអញ្ចឹងគេខឹងខ្ញុំ ហើយគេថានៅកន្លែងហ្នឹងក៏នៅមិនបានដែរ ។

ហៀង ៖ ពីណាគេជាអ្នកនិយាយពាក្យហ្នឹង?

ទឹម ៖ យាយរឿន ហ្នឹង ។

ហៀង ៖ មកនិយាយជាមួយមីងពេលណាទៅ?

ទឹម ៖ និយាយពេលដូចថាប្រជុំអញ្ចឹងហៅខ្ញុំមកស្តីឲ្យហើយ ។

ហៀង ៖ ប្រជុំគ្នាច្រើនឬក៏ប្រជុំតែម្នាក់?

ទឹម ៖ ប្រជុំមួយពេទ្យហ្នឹងទាំងអស់ ។

ហៀង ៖ ទាំង១០នាក់ហ្នឹង?

ទឹម ៖ ចា៎! សម្លុតខ្ញុំយកៗ ។

ហៀង ៖ សម្លុតយ៉ាងម៉េចខ្លះទៅមីង?

ទឹម ៖ សម្លុតថាបើនាងឯងមិនធ្វើតាមខ្ញុំទេ នាងឯងមានតែឲ្យទៅតាមស្រុកយកទៅវ៉ៃចោល ហើយខ្ញុំខ្លាចអត់ហ៊ានតវ៉ាទេ ឲ្យទៅណាក៏ទៅដែរ សុខចិត្តទៅធ្លាប់ម្តងចុះ ។

ហៀង ៖ និយាយហ្នឹងមីងមានចាំទេ កាលហ្នឹងគាត់និយាយនៅពេលណាដែរ ប្រហែលពេលណាទៅ ហើយម៉ោងប្រហែលប៉ុន្មានដែរ?

ទឹម ៖ ចាំថា ពេលនិយាយម៉ោង១២អញ្ចឹងចុះ សហករណ៍ហៅសម្រាកអញ្ចឹងគេប្រជុំពួកពេទ្យ អញ្ចឹងណាគេហៅមកស្តី ។

ហៀង ៖ គេប្រជុំរាល់ថ្ងៃមែន?

ទីម ៖ អត់ទេគេប្រជុំនៅពេលដែលគ្នាយើងនៅក្នុកក្តាន់ ហើយឃើញថាពេលយើងហូបអញ្ចឹងអត់សហករណ៍ហូបដែរ គ្រាន់ថាចង់ឲ្យសហករណ៍ហូបបាយរាងរីងបន្តិចហ្នឹង ថានៅជាមួយគ្នាវាកោសរូងយើងណាស់ ដូចថាខ្ញុំហ្នឹងធ្វើអត់ល្អអញ្ចឹងណា៎ ឲ្យអ្នកជម្ងឺហូបគោកអញ្ចឹងណា៎ អាហ្នឹងគេហៅខ្លាំងបន្តុប់ហើយ ។

ហៀង ៖ គេអត់ឲ្យញ៉ាំគោកទេមីង?

ទីម ៖ អត់ឲ្យញ៉ាំបាយគោកទេ ដឹងតែបបររាវហ្នុង មួយថ្ងៃ៣ដងអាហ្នឹងសម្រាប់អ្នកជម្ងឺហ្នឹង ហើយអញ្ចឹងពួកពេទ្យ ពួកប្រធាន ពួកសមាជិកហ្នឹងវាស៊ីបាយរឹងទាំងអស់ ហើយវាធ្វើបាប យើងណាស់ ។

ហៀង ៖ ហើយមានម្ហូបអីទៅមីង?

ទីម ៖ ម្ហូបវាមាន គេហូបសាច់មាន់ហើយនឹងត្រីអញ្ចឹងទៅ ហើយយើងនៅតាមសហករណ៍មានអីអូន ហូបតែព្រលិត អន្ទុំ បបរ ប៉ុណ្ណឹងប្រាវទៅបង់តែអំបិលទៅចប់ហើយ ។

ហៀង ៖ ហើយបានម្ហូបមកពីណាមីង ក្រែងគេថាឲ្យស្មើរគ្នាមែនទេ?

ទីម ៖ អត់មានស្មើរគ្នាទេ អញ្ចឹងខ្ញុំបានខ្ញុំថាប្រធានអត់មានស្មើរគ្នាទេ គេធ្វើបាបយើងតាមដួងចិត្តដូចគ្នា ។

ហៀង ៖ អញ្ចឹងបានន័យកាលជំនាន់ខ្មែរក្រហមពួកវាថាឲ្យស្មើរគ្នា តែអត់ឲ្យស្មើរគ្នាទេ?

ទីម ៖ អត់មានស្មើរគ្នាទេ ប្រធានហូបលួចលាក់ ។

ហៀង ៖ ហូបលួចលាក់?

ទីម ៖ ហូបលួចលាក់ ហើយពេលដែលយើងមើលឃើញគេមានឃើញឆាមាន់ជាមួយខ្ញីអញ្ចឹងទៅដល់ពេលយើងអាណិតសហករណ៍ ពេទ្យអាតូចតាចគេអត់ឲ្យហូបទេណា៎ ហូបតាមសហករណ៍ សហករណ៍ហូបម៉េចគេឲ្យហូបអញ្ចឹង ។

ហៀង ៖ មីងអ្នកធំដែលថាញ៉ាំអីជាមួយគ្នាហ្នឹងមានតែប្រធានហើយហ្នឹងអនុប្រធានទេ?

ទីម ៖ មានតែ៣នាក់ហ្នឹងទេដែលហូប ។

ហៀង ៖ ក្រៅពីហ្នឹងអត់មានអ្នកណាទេ?

ទីម ៖ អត់មានអ្នកណាហ៊ានលូកដៃហូបជាមួយគេទេ ហើយមើលឃើញគេអាប្រពន្ធកម្មាភិបាល ហើយនឹងអ្នកអ្នកធ្វើបាយក៏អត់ឲ្យយើងធ្វើទៀត ប្រធានគេចាប់ធ្វើខ្លួនគេទៀត ខ អាំង ចៀន ស្ងោរអីហ្នឹង សហករណ៍បិទបាំងមិនឲ្យឃើញទេ គេកម្មាភិបាល គណៈស្រុកហ្នឹងគេបិទមិនឲ្យឃើញទេ ហើយយើងប្រជាជនធម្មតាហូបអញ្ចឹងទៅ ។

ហៀង ៖ គេហូបនៅណាដែរមីង?

ទីម ៖ ហូបនៅកន្លែងហ្នឹង ។

ហៀង ៖ មីងនិយាយហ្នឹងនៅក្នុងវត្តមែន?

ទីម ៖ ក្នុងវត្ត ។

ហៀង ៖ ក្នុងវត្តហ្នឹងមានកម្មាភិបាលមកដែរមីង?

ទីម ៖ កម្មាភិបាលប្រធានក្រុមយើងហ្នឹង ។

ហៀង ៖ ប្រធានក្រុមមីង?

ទីម ៖ ពួកប្រធានហ្នឹង ។

ហៀង ៖ ហើយវាញ៉ាំតែ៣-៤នាក់ហ្នឹងឬក៏ញ៉ាំជាមួយអ្នកណាទៀត?

ទីម ៖ ញ៉ាំគ្នាវាតែ៣នាក់ហ្នឹងទេ ។

ហៀង ៖ និយាយពីប្រជុំ គេអាសារប្រជុំទេ?

ទីម ៖ អាសារប្រជុំ ឲ្យតែឃើញយើងធ្វើខុសអីគេប្រជុំហើយ ។

ហៀង ៖ តែជារឿយៗគេប្រជុំប៉ុន្មានថ្ងៃម្តង?

ទីម ៖ ៣ថ្ងៃម្តង យើងមើលឃើញប្រធានធ្វើខុសអញ្ចឹង អញ្ចឹងពូកែកសាងពេកទៅប្រជុំធំ ដូចថាស្រុកអញ្ចឹងមកប្រជុំលើកទីមួយដូចថាគាត់កំណត់ធ្វើបាបយើងអញ្ចឹងណា៎ ទីមួយ ធ្វើបាបអ្នកជម្ងឺ ទីពីរសហករណ៍ឲ្យម្ហូបដូចថារបបពីសហករណ៍ដូចជាបន្លែមអញ្ចឹង ពោតអញ្ចឹងមកឲ្យសហករណ៍អ៊ីៗហ្នឹងអត់ឲ្យយើងហូបសុខចិត្តចាក់ចោល ទីពីរយើងគុំចាំមើលគាត់ ដល់ពេលអញ្ចឹងដល់ពេលដែលប្រជុំធំកន្លែងស្រុកហ្នឹង ។

ហៀង ៖ ថ្ងៃណា មីងមានចាំទេ មីងមានចាំថ្ងៃខែទេ?

ទីម ៖ អត់បានចាំផង ។

ហៀង ៖ តែមីងនៅបានប្រហែលបានប៉ុន្មានខែទៅបានគេបញ្ជូនមីងទៅ?

ទីម ៖ នៅក្នុងហ្នឹងប្រហែលជាបាន៣ខែ ។

ហៀង ៖ ម៉េញមីងថានៅបានប្រហែលជា២ខែ?

ទីម ៖ ដល់ពេលនៅអញ្ចឹងខ្ញុំចេះតែតាមដានយាយបុំហ្នឹង ។

ហៀង ៖ យាយរឿន ហ្នឹងមែន?

ទីម ៖ ហ្នឹងអើយ ធ្វើបាបណាស់ ធ្វើបាបសហករណ៍ ហើយអាពេទ្យតូចតាចហ្នឹងក៏ធ្វើបាបគ្នាហើយតាមដានរហូតថាមុខនាងឯងដូចអា ធៀវ គឺ ចាប់ដាក់រថក្រោះអញ្ចឹងណា ហើយខ្ញុំ

ថាទីពីរទីបីកសាងខ្ញុំឲ្យរាល់ពេល ហើយគំនិតគាត់ហូបបាយលួចលាក់ អញ្ចឹងដល់ពេលប្រជុំស្រុកខ្ញុំឡើងនិយាយ ទីមួយកសាងខ្លួនខ្ញុំប្រហែលខ្លាំងដូចអា ធៀវ គឺ ទីបីអ្នកជម្ងឺហូបបាយទីបួនសហករណ៍ឲ្យមក តាមសហករណ៍អ្នកធំឲ្យមកហូបតែអត់ឲ្យអ្នកជម្ងឺហូបទេ យកទៅចាក់ចោលនៅគុម្ពឬស្សី ឈ្លោះគ្នាត្រឹមហ្នឹង ដល់ហើយឲ្យខ្ញុំចេញភ្លាម ។

ហៀង : មីងឡើងនិយាយនៅកន្លែងណា?

ទឹម : នៅស្រុក ហើយប្រជុំធំអញ្ចឹងមានកម្មាភិបាល ប្រធានភូមិ ប្រធានក្រុមអញ្ចឹងទៅ ។

ហៀង : នៅណាមីង?

ទឹម : នៅកន្លែងស្រុក១០៩ ។

ហៀង : ប្រជុំនៅកន្លែងណាមីងមានចាំទេ?

ទឹម : ប្រជុំនៅកន្លែងផ្ទះគេហ្នឹង ។

ហៀង : ផ្ទះពីណាគេ?

ទឹម : នៅស្នាក់ការគេ ។

ហៀង : នៅស្នាក់ការហ្នឹងហ្មង?

ទឹម : ចា៎!

ហៀង : មានមនុស្សប្រហែលជាប៉ុន្មាននាក់ មីងមានចាំទេ?

ទឹម : រាប់រយនាក់ ។

ហៀង : ពីណាគេអ្នកធំនៅហ្នឹង?

ទឹម : អ្នកធំហ្នឹង យឿន ហ្នឹងហ្មង ។

ហៀង : យឿន ហ្នឹងមកតែម្តង?

ទឹម : ចា៎!

ហៀង : អត់មានពីណាគេធំជាងយាយ យឿន ទៀតទេ?

ទឹម : អត់មានទេ ។

ហៀង : អ្នកដែលចូលរួមហ្នឹងមានយាយ យឿន មួយធំជាងគេ?

ទឹម : ចា៎! ហើយខ្ញុំបានអះអាងមិនបានកសាងយាយហ្នឹង ខ្ញុំធ្លាប់នៅជាមួយគណៈស្រុកហ្នឹង ហើយគាត់ចេះតែសម្លុតខ្ញុំធ្វើបាបខ្ញុំ ទី១ខ្ញុំចាំគាត់កត់អញ្ចឹង ទី២ចាំជួបគាត់ ហើយគាត់ធ្វើបាបខ្ញុំអញ្ចឹង ធ្វើបាបសហករណ៍រួមគ្នា អញ្ចឹងខ្ញុំរាយការណ៍ទៅ ដល់ហើយយាយហ្នឹងនៅហ្នឹងរហូត សុខចិត្តបំបែកឲ្យខ្ញុំចេញវិញ ឲ្យខ្ញុំចេញមកនៅតាមភូមិវិញ ។

ហៀង :

មីងមានចាំទេថាមីងនៅក្នុងពេទ្យហ្នឹងប្រហែលជាប៉ុន្មានថ្ងៃប៉ុន្មានខែដែរបានមីងមានប្រជុំធំនៅ ស្រុកហ្នឹង?

ទីម : ពេលប្រជុំធំប្រហែលជាមួយខែ មួយខែជាងបានប្រជុំ ។

ហៀង : អញ្ចឹង?

ទីម : ចាំ!

ហៀង : ចុះមីងគ្រាន់តែនិយាយហើយបានប៉ុន្មានថ្ងៃប៉ុន្មានខែបានគេដេញមីងចេញឲ្យទៅនៅតាមសហករណ៍?

ទីម : អាហ្នឹងនិយាយបានតែ៣ថ្ងៃគេដេញចេញ ។

ហៀង : តែអំឡុងពេលដែលនិយាយភ្លាម មីងមានឃើញអំឡុងពេលថ្ងៃដែលមីងនៅក្នុងពេទ្យហ្នឹងដដែល ហើយយាយ រឿន ដែលថាមីងរាយការណ៍ហ្នឹងយាយ រឿន មានធ្វើអីដាក់មីងទេដូចថាមានសម្ពុតទេ?

ទីម : សម្ពុតថាទុកឲ្យខ្ញុំនៅកន្លែងហ្នឹងក៏មិនបានដែរ មានតែយកវ៉ៃចោល បើមិនវ៉ៃចោលមានតែបំបិទភស្តុតាងសហករណ៍ មកប្រាប់យាយ ឃឿន ហើយនឹងយាយ រឿន ហ្នឹងព្រោះអីសាច់ឈាមគេណាំ ហើយពេលហ្នឹងខ្ញុំក៏រាងអត់ខ្លាចព្រោះធ្លាប់នៅជាមួយយាយ ឃឿន ហ្នឹងណាំ បានខ្ញុំរាយការណ៍យាយ រឿន ហ្នឹងហើយយាយ រឿន ហ្នឹងធ្វើបាបខ្ញុំ ។

ហៀង : ហើយដល់ពេលអញ្ចឹងទៅក៏បញ្ជូនទៅនៅតាមសហករណ៍?

ទីម : ចាំ!

ហៀង : ហើយអ្នកណាគេជាអ្នកបញ្ជូនមីងទៅនៅតាមសហករណ៍ យាយឃឿន ឬក៏យាយរឿន?

ទីម : យាយឃឿន ជាអ្នកបញ្ជូន ។

ហៀង : គាត់មកជួបមីងផ្ទាល់ឬមួយក៏គាត់ឲ្យសំបុត្រឲ្យក្រដាសអី?

ទីម : គាត់ឲ្យខ្ញុំចេញ យាយរឿន ថាឥលូវនារីឯងចេញទៅ ដល់ហើយខ្ញុំថាខ្ញុំមិនចេញទេ ទាល់តែយាយ ឃឿន ថាឲ្យខ្ញុំចេញបានខ្ញុំចេញ ។

ហៀង : គាត់មកជួបមីងផ្ទាល់ឬមួយក៏គាត់ឲ្យសំបុត្រ?

ទីម : មកជួបផ្ទាល់ ហើយគាត់ថាឯងចេញទៅ ព្រោះអីចេញទៅវាមានគ្នាច្រើននាក់ដែរ អាមិនត្រូវគ្នាហ្នឹងធ្វើបាបពួកក្រុមខ្ញុំណាស់ មិនចេះសោះហ្នឹងគេចេះតែធ្វើបាប ។

ហៀង : ធ្វើបាបយ៉ាងម៉េចខ្លះទៅមីង?

ទឹម ៖ ធ្វើបាបពេលយើងហូបបាយអញ្ចឹងគេតាមដានយើង ហើយពេលហូបបបររាងគោកបន្តិចក៏មិនបានដែរ ។

ហៀង ៖ ហើយក្រៅពីហូបចុកគេមានធ្វើបាបអីទៀតទេ?

ទឹម ៖ គេអត់មានធ្វើបាបអីទេ គ្រាន់ថាពាក្យសំដីវេនអ្នកនេះអ្នកនោះអញ្ចឹង យាមឲ្យត្រឹមត្រូវប្រយ័ត្នអ្នកជម្ងឺម៉េចៗ ហើយពេលអ្នកជម្ងឺឈឺស្រែកចង់អាយះបំពង់កក៏មិនយកចិត្តទុកដាក់ដែរ ហើយដល់នេះខ្ញុំអាណិតតែអ្នកជម្ងឺទេ ថ្នាំលេបទៀតហើយ ចាក់ទៀតហើយ ហើយអាចាក់ហ្នឹងភ័យផងញាក់ផង ហើយអ៊ីមួយគាត់ស្រែកថាអូនអើយជួយផង អ៊ីពិបាកណាស់ឃ្លានណាស់ ហើយខ្ញុំថាអ៊ីអើយ ទោះបីជាឃ្លានយ៉ាងណាខ្ញុំហើយនឹងអ៊ីឯងដូចតែគ្នាហ្នឹង ខ្ញុំមិនហ៊ានលួចទៀតទេ អាប្រជុំញីកញាប់ហ្នឹងខ្លាចណាស់ អ៊ីឯងមិនជួយខ្ញុំធ្វើយ៉ាងម៉េច ។

ហៀង ៖ មីងមានដឹងទេ ភាគច្រើនដូចជាថ្នាំពេទ្យ ដូចជាម្ហូបអញ្ចឹងគេយកពីណាវិញមីង?

ទឹម ៖ កន្លែងហ្នឹងមានអគ្គការគេបើកឲ្យប្រើ ។

ហៀង ៖ ពីណាគេជាអ្នកបើកឲ្យ?

ទឹម ៖ គណៈស្រុកហ្នឹង?

ហៀង ៖ មីងមានចាំទេ ពេលដែលយាយ យឿន មកហៅមីងចេញហ្នឹងខ្វង់ប្រហែលជាប៉ុន្មានថ្ងៃក្រោយទៅ?

ទឹម ៖ ៣ថ្ងៃ រឿងវាចេះតែទាស់ជាមួយពេទ្យ ហើយក៏ចេញទៅ ។

ហៀង ៖ អញ្ចឹងបន្ទាប់មកទៀតមានដឹងមានរឿងអីកើតឡើងនៅក្នុងពេទ្យហ្នឹងទៀតទេ?

ទឹម ៖ រឿងកើតនៅក្នុងពេទ្យវាចេះតែកើតហើយ វាចេះតែគម្រាម សម្លុតអញ្ចេះអញ្ចោះ ថាឲ្យសហករណ៍ឲ្យរួចតែពីរមាត់ហ្នឹង ខ្ញុំថាអ៊ីឯងទាំងអស់គ្នាចង់ឲ្យគេរៃបោលក្នុងអន្លង់ទាំងអស់គ្នា ។

ហៀង ៖ ពីណាគេអ្នកនិយាយ?

ទឹម ៖ យាយ រឿន ហ្នឹង ថ្ងៃណានេះគាត់សម្លុតអញ្ចឹងទៅ ដូចជាស្រាថ្នាំស្រាអីអញ្ចឹងទៅអាណា លួគេទុកហិតខ្លួនគេ ដូចថាកម្មាភិបាលអញ្ចឹងគេហិតឆ្ងាញ់ៗអញ្ចឹងទៅ ហើយយើងក្រៅពីហ្នឹងមានស្អីដឹកមានតែទឹក សូម្បីតែដឹកទឹកហ្នឹងក៏មិនចង់ឆ្អែតដែរ ។

ហៀង ៖ ចុះមីងពេលដែលមីងតមាត់ជាមួយយាយ រឿន ហ្នឹងមីងខ្លាចទេ?

ទឹម ៖ អត់ខ្លាចទេ ។

ហៀង ៖ ហេតុអីបានជាមីងអត់ខ្លាច?

ទីម ៖ អត់ខ្លាចព្រោះពីមុនមានដែលកសាងណា ហើយមានយាយ ឃឿន ហ្នឹងជាសាក្សី ហើយយាយឃឿន ហ្នឹងទោះបីម៉េចក៏គាត់នឹកឃើញអប់រំយើងដែរ ហើយគាត់ហ្នឹងក៏គាត់មិនធ្វើអីយើងដែរ ហើយដល់ពេលសម្លុតមែនទែនទៅឲ្យខ្ញុំចេញហ្នឹងខ្ញុំភ័យដែរ ខ្លាចគេយកទៅវ៉ៃចោល ។

ហៀង ៖ គាត់សម្លុតម៉េចទៅមីង?

ទីម ៖ យាយរឿន គាត់សម្លុតថា ពួកឯងគ្រប់គ្នាដឹងហើយថាទៅនៅហ្នឹង ឲ្យពួកឯងវេទនាមួយជីវិត គាត់ហោះសំដីអញ្ចឹងទៀតណា៎ មិនធម្មតាទេយាយហ្នឹង ។

ហៀង ៖ កាចដែរមីង?

ទីម ៖ កាចណាស់ ។

ហៀង ៖ មីងមានដែលឃើញ យាយរឿន ហ្នឹងស្តីបន្ទោសអ្នកជម្ងឺទេមីង?

ទីម ៖ ស្តីដូចតែគ្នាហ្នឹង ។

ហៀង ៖ មីងយល់ថាអ្នកជម្ងឺកាន់តែឈឺទៅឬមួយក៏កាន់តែជាទៅ?

ទីម ៖ អ្នកជម្ងឺកាន់តែឈឺទៅ អាខ្លះឈឺស្រែកហៅពេទ្យហ្នឹងអត់មានអ្នកណាជួយទេ ហើយខ្ញុំចេះតែអាណិតពេលដែលអ្នកជម្ងឺហៅខ្ញុំឡើងទៅ ។

ហៀង ៖ ចុះភាគច្រើនអ្នកជម្ងឺដែលទៅហ្នឹងច្រើនជាឬមួយក៏?

ទីម ៖ ច្រើនជា ។

ហៀង ៖ ថ្នាំពេទ្យអត់គ្រប់គ្រាន់អញ្ចឹងជាដែរ?

ទីម ៖ វាគ្មានរឿងអីថាមិនឲ្យជានោះទេ ទៅណាបានឲ្យឆាប់ជាអាងបានទៅផ្ទះ ។

ហៀង ៖ ពេលជាហ្នឹងគេមានចេញលិខិតស្នាមអីទេ?

ទីម ៖ អត់មានចេញលិខិតស្នាមអីទេ ឲ្យតែហូបបាន បបរច្រើនអញ្ចឹងទៅ ហើយអ្នកណានៅកន្ទ្រិបកន្ទ្របក៏នៅទៅ ហើយអ្នកណាដើររួចចេញទៅ ។

ហៀង ៖ ពីណាគេអ្នកឲ្យចេញ?

ទីម ៖ ប្រធានគេហ្នឹង ។

ហៀង ៖ ហើយយាយ រឿន ហ្នឹងអត់មានសរសេរលិខិតស្នាមដូចថាអ្នកនេះអាចចេញបានហើយអញ្ចឹងអត់មានសរសេរលិខិតស្នាមអីទាំងអស់?

ទីម ៖ អត់ទេ ។

ហៀង ៖ ហើយពេលអ្នកចូលមកមន្ទីរពេទ្យហ្នឹងមានលិខិតអីទេ?

ទីម ៖ អត់មានលិខិតអីទេ ។

ហៀង ៖ ពីណាគេជាអ្នកបញ្ជូន?

ទីម ៖ តាមសហករណ៍ ។

ហៀង ៖ ចុះពេលឈឺធ្ងន់អញ្ចឹងពីណាគេជាអ្នកបញ្ជូនមកពេទ្យ?

ទីម ៖ អ្នកឈឺធ្ងន់តាមសហករណ៍អញ្ចឹងគេបញ្ជូនមកពេទ្យហើយ ។

ហៀង ៖ ពីណាគេជាអ្នកបញ្ជូនមីងមានដឹងទេ?

ទីម ៖ តាមភូមិតាមក្រុមហ្នឹង ។

ហៀង ៖ មេភូមិមេក្រុមហ្នឹងជាអ្នកបញ្ជូនអ្នកជម្ងឺមក?

ទីម ៖ ចាំ!

ហៀង ៖ ហើយភាគច្រើនពេលដែលបញ្ជូនមកហ្នឹងជិះអីមក?

ទីម ៖ គ្មានជិះស្អីទេ សុទ្ធតែឲ្យដើរទាំងអស់ហ្នឹង ។

ហៀង ៖ ដើរទាំងឈឺ?

ទីម ៖ ចាំ! ដើរមកដល់ពេទ្យទាំងឈឺ ។

ហៀង ៖ អញ្ចឹងពេលយាយ ឃឿន ឲ្យមីងចេញក្លាមមីងចេញហ្មង?

ទីម ៖ ប្រហែលជារំលងបាន៣ថ្ងៃខ្ញុំចេញ ។

ហៀង ៖ ដល់ពេលហើយទៅមីងទៅនៅភូមិណាទៅ?

ទីម ៖ នៅភូមិត្រយឹង ។

ហៀង ៖ នៅត្រយឹងបានប្រហែលជាប៉ុន្មានខែទៅ ។

ទីម ៖ នៅភូមិត្រយឹងនៅបានប្រហែលជា២ខែ ដល់ហើយមកតាមសហករណ៍វិញ ។

ហៀង ៖ ទៅភូមិត្រយឹងមីងធ្វើអី?

ទីម ៖ ទៅនៅជាមួយគ្នាមួយដុំហ្នឹង នាំគ្នាមកដេរវិញ ។

ហៀង ៖ អញ្ចឹងចេញពីពេទ្យហើយមីងមកដេរវិញទៀត?

ទីម ៖ ចាំ! ដេរខោអាវពួកទ័ព ។

ហៀង ៖ អញ្ចឹងដេរឲ្យទ័ពម្តង?

ទីម ៖ ចាំ!

ហៀង ៖ ពួកទ័ពស្លៀកពាក់ខោអាវពណ៌អី?

ទីម ៖ ខោអាវខ្មៅ ។

ហៀង ៖ មានខុសគ្នាជាមួយប្រជាជនមូលដ្ឋានទេ?

ទឹម ៖ អត់ទេ ។

ហៀង ៖ ពាក់ខោអាវដូចគ្នាតែម្ដង អត់មានខុសម៉ូដខុសអីទេមីង?

ទឹម ៖ អត់មានខុសម៉ូដទេ ចុះបើខោអាវដេរត្រង់ៗ ។

ហៀង ៖ អញ្ចឹងមីងដេរឲ្យទ័ពហ្នឹង ដេរបានប្រហែលជា២ខែដែរ?

ទឹម ៖ ដេរបានប្រហែលជា២-៣ខែ ។

ហៀង ៖ ហើយពីណាគេជាអ្នកឲ្យមីងមកដេរវិញ?

ទឹម ៖ យាយយឿន ហ្នឹង ។

ហៀង ៖ យាយយឿន ហ្នឹងឲ្យមីងមកដេរនៅភូមិត្រយឹងហ្នឹង?

ទឹម ៖ ចាំ!

ហៀង ៖ ហើយនៅគ្នាប្រហែលជាប៉ុន្មាននាក់ទៅ?

ទឹម ៖ នៅគ្នាប្រហែលជា៥-៦នាក់ ។

ហៀង ៖ មីងមានចាំគ្នាមីងទេ?

ទឹម ៖ ចាំ! ប៉ុន្តែសុទ្ធតែអ្នកស្រុក១០៥ហ្នឹងទាំងអស់ ។

ហៀង ៖ មីងនៅដេរអញ្ចឹង ក្នុងមួយថ្ងៃមីងដេរបានប៉ុន្មានទៅ?

ទឹម ៖ ដល់ពេលហ្នឹងដេរខោអាវបានក្នុងមួយថ្ងៃបានជិត២០កំប្លេ ។

ហៀង ៖ ស្ទាត់ហ្នងមីង?

ទឹម ៖ ចុះដេរត្រង់ៗហ្នឹង ចេះតែប្រឹងទៅ បើមិនប្រឹងមិនកើត ។

ហៀង ៖ ហើយមីងធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ទឹម ៖ តាំងតែពីព្រលឹមទល់យប់ ហើយយប់ជិតភ្លឺទៀតហ្នឹងណាំ គ្មានបានដេកទេគ្មានពេលធ្វើអីទេ

ហៀង ៖ ម៉ោងប៉ុន្មានមីងភ្ញាក់ធ្វើការ?

ទឹម ៖ គ្មានរឿងគ្មានម៉ោងទេ ដឹងតែពីព្រលឹមអញ្ចឹង ភ្លឺច្បាស់ដឹងតែដេរ ហើយយប់ឡើងដឹងតែ
ដុតចង្កៀងមាុំស្រេគ អាចង្កៀងដាក់ប្រេងគេហ្នឹង កាលហ្នឹងសំបូរណាស់ ។

ហៀង ៖ ហើយដេរហើយបញ្ជូនទៅខាងណាវិញ?

ទឹម ៖ ពេលបញ្ជូនៗទៅទ័ព ហើយគ្មានអ្នកណាប្រធានទេ ។

ហៀង ៖ អ្នកណាគេជាអ្នកកាន់កាប់មីង?

ទីម ៖ គ្មានអ្នកណាកាន់កាប់ទេ ហើយអត់ទាន់មានប្រធានមានអីទេ ដល់ពេលអត់មានប្រធានមានអីអញ្ចឹងគាត់ខោអាវស្បៀកពាក់ផ្ញើម៉ាសាអញ្ចឹងលួចឲ្យសហករណ៍ ដល់ពេលលួចឲ្យអញ្ចឹងគេថាអូនឯងលោក់ឲ្យជិតណាំ បើលោក់មិនជិតអូនឯងប្រយ័ត្នគេរករឿងមេ ។

ហៀង ៖ មីងស្គាល់គេមែនទេ?

ទីម ៖ ស្គាល់ ។

ហៀង ៖ ម្នាក់ហ្នឹងពីណាគេ?

ទីម ៖ ស្គាល់នៅស្រុកខាងលិចភ្នំ សាច់ឈាមខ្ញុំហ្នឹងហ្នង ដល់ពេលឲ្យកូនហ្នឹងអត់បានស្បៀកពាក់ទេ ហើយដឹងគុណខ្ញុំដល់ឥលូវណាំ គេថាទោះបីគេក្រយ៉ាងណាក៏គេជួយមីងឯងដែរ ឥលូវគេមានផ្ទះសម្បែងធំៗ ហើយគេកូនកំព្រាណា ទាំង២នាក់ហ្នឹងខ្ញុំចេះតែអាណិតឲ្យទៅ ហើយវាអត់បានស្បៀកពាក់ទេ កូនកម្មាភិបាល អាវអត់បានទុកស្បៀកពាក់ទេខ្លាចគេវៃចោល ។

ហៀង ៖ ចុះមីងខោអាវហ្នឹងគេបញ្ជូនទៅទ័ពខាងណាវិញ?

ទីម ៖ ទ័ពកន្លែងស្រុកហ្នឹង ។

ហៀង ៖ ស្រុក១០៩ហ្នឹង?

ទីម ៖ ចាំ!

ហៀង ៖ អញ្ចឹងមីងនៅក្នុងនោះមានគ្នាប្រហែលជាប៉ុន្មាននាក់ទៅកាត់ដេរហ្នឹង?

ទីម ៖ គ្នាមានតែ៦នាក់ស្រីៗហ្នឹង ។

ហៀង ៖ ស្រីៗ៦នាក់ហ្នឹងមកពីណាមីង?

ទីម ៖ មកពីស្រុកផ្សេងៗគ្នាទាំងអស់ ។

ហៀង ៖ អញ្ចឹងម៉េចបានជាមីងចេញពីកន្លែងកាត់ដេរហ្នឹង?

ទីម ៖ ដល់នេះគេឲ្យឈប់ហើយឲ្យមកនៅកន្លែងសហករណ៍ញ៉ាំមហូងទៅ ។

ហៀង ៖ ពីណាគេជាអ្នកឲ្យមីងឈប់ពីកន្លែងកាត់ដេរហ្នឹង?

ទីម ៖ កន្លែងឃុំគេឲ្យឈប់ ។

ហៀង ៖ ម៉េចអញ្ចឹងមីង?

ទីម ៖ គេឲ្យយើងប្ដូរៗតាមភូមិ ទៅប្ដូរនៅឃុំអញ្ចឹងរាប់រយគួរ ។

ហៀង ៖ ឃុំអីគេមីង?

ទីម ៖ ឃុំរាមអណ្ដើក ។

ហៀង ៖ ក្រែងមីងថានៅភូមិក្រយឹង?

ទីម ៖ ពេលទៅនៅគឺនៅភូមិត្រយឹង ចេញពីរាមអណ្ដើកហ្នឹងទៅនៅត្រយឹង ដល់ពេលទៅនៅតាមសហករណ៍ ប្ដូរជាតាមសហករណ៍ ធ្វើដីអាចម៍អីពេញទឹកពេញដី តាមផ្ទះតាមអីហ្នឹងដើរកាយអាចម៍កាយអីទៅយកទៅធ្វើបាចដីស្រូវទៅលាយជាមួយអីបន្តិចទៅ ហើយយាយខ្វះគាត់ថាឯងអើយមិនដឹងធ្វើម៉េចទេ រាល់ថ្ងៃខ្លាចតែគេវៃចោលទេ ហើយខ្ញុំថាទាំងយាយឯងទាំងខ្ញុំធ្វើម៉េចទេយាយអើយ ពិបាកអញ្ចឹងណា៎ មិនដឹងអ្នកណារស់អ្នកណាស្លាប់ទេ។

ហៀង ៖ អញ្ចឹងមីង ពេលដែលមីងត្រលប់មកភូមិរាមអណ្ដើកវិញ?

ទីម ៖ ទៅនៅត្រពាំងវន្ទ។

ហៀង ៖ ហើយមីងការនូវពេលហ្នឹង?

ទីម ៖ ប្ដូរជាហើយ។

ហៀង ៖ ប្ដូរជានៅកន្លែងណាមីង?

ទីម ៖ ប្ដូរជានៅមាត់ព្រៃម្តេង។

ហៀង ៖ ភូមិឃុំអីដែរ?

ទីម ៖ ភូមិព្រៃម្តេងហ្នឹងហ្នង។

ហៀង ៖ ហើយប្រហែលជាប៉ុន្មានគូរទៅពេលដែលប្ដូរជាហ្នឹង?

ទីម ៖ ប្រហែលជា១០គូរ ពេលយប់ហ្នឹង។

ហៀង ៖ ពេលយប់ហ្នង?

ទីម ៖ ចា៎!

ហៀង ៖ ហើយមីងពេលប្ដូរជាជាមួយអ្នកណាគេ?

ទីម ៖ ប្ដូជាមួយ នេន ឆែម ហ្នឹង។

ហៀង ៖ ហើយគាត់ហ្នឹងធ្វើអីដែរកាលហ្នឹង?

ទីម ៖ គាត់ហ្នឹងធ្វើប្រធានភូមិ។

ហៀង ៖ ប្រធានភូមិនៅណា?

ទីម ៖ ប្រធានភូមិត្រពាំងវន្ទ។

ហៀង ៖ តែមីងប្ដូរជានៅមាត់ព្រៃម្តេង?

ទីម ៖ ចា៎!

ហៀង ៖ អញ្ចឹងពេលមីងប្ដូរជាហើយមីងក៏មកនៅជាមួយគ្រួសាររបស់មីង?

ទីម ៖ ចា៎!

ហៀង ៖ អញ្ចឹងពេលមីងមកនៅជាមួយគ្រួសាររបស់មីង តើមីងធ្វើអីដែរ?

ទីម ៖ គេឲ្យធ្វើដីអាចម៍ ។

ហៀង ៖ ហើយដល់ពេលគ្រួសាររបស់មីងធ្វើមេភូមិ?

ទីម ៖ ធ្វើមេភូមិ ។

ហៀង ៖ ហើយមីងមកនៅជាមួយគ្រួសាររបស់មីងរហូត?

ទីម ៖ មកនៅជាមួយរហូត តែដឹងតែបែកផ្លូវគ្នាធ្វើការ ទៅលើកដីតាមក្រុមតាមគ្នាយើងអញ្ចឹងទៅ ដើរទៅតាមមាត់បឹងកាប់ដីកាប់អី ។

ហៀង ៖ មីងអត់មានបែកគ្នាណា?

ទីម ៖ បែកគ្នារហូត ។

ហៀង ៖ ក្រែងគាត់មេភូមិអញ្ចឹងតិចអាច?

ទីម ៖ គ្មានទេ មេភូមិណាទៅអាចគាំទ្រកម្លាំងយើងឲ្យនៅផ្ទះបាននោះទេ អញ្ចឹងគេម៉េចហ្នឹងគេយកចិត្តទុកដាក់ ដល់អញ្ចឹងមិនចេញទាំងអស់គ្នា ក្បាលអាណាសក់អាហ្នឹងហើយ ។

ហៀង ៖ មីងកាលបានមកជួបគ្នាម្ដង?

ទីម ៖ រឿងជួបគ្នាមិនសូវមានទេ ខ្លះគេថាមួយអាទិត្យជួបគ្នាម្ដង ខ្ញុំអត់ទេ ។

ហៀង ៖ អញ្ចឹងកាលទៅបានមកជួបគ្នាម្ដង មីងនៅធ្វើការនៅណាទៅមីង?

ទីម ៖ ធ្វើការនៅតាមស្រែ ។

ហៀង ៖ តែនៅខាងភូមិហ្នឹងដដែលទេ?

ទីម ៖ នៅភូមិហ្នឹងដដែលតែនៅស្រែក្រោម ។

ហៀង ៖ ហើយមីងនៅហ្នឹងហ្មង?

ទីម ៖ នៅតាមកងចល័តយើងមួយក្រុមៗអញ្ចឹងណា ។

ហៀង ៖ តែមីងអត់ត្រលប់មកផ្ទះវិញទេ?

ទីម ៖ អត់មកផ្ទះទេ ។

ហៀង ៖ ហើយកាលបានត្រលប់មកវិញ?

ទីម ៖ ប្រហែលជា២អាទិត្យអញ្ចឹងត្រលប់មក ជួនកាលអត់មកអញ្ចឹងទៅ ចុះនៅគ្នាច្រើនអញ្ចឹងចេះតែនៅធ្វើអញ្ចឹង ។

ហៀង ៖ ហើយមីងនៅដល់ប្រហែលជាប៉ុន្មានខែទៅបានបែក?

ទឹម ៖ បើគិតៗទៅអាពួកធំហ្នឹងមិនប៉ុន្មានទេ ប៉ុន្មានខែបានបែក មិនដម្លៀសហើយមិតទៅលើ ហើយកាល ប៉ុល ពត ហ្នឹងរត់ពីលើ ។

ហៀង ៖ បែកបាក់?

ទឹម ៖ បែកទៅកាលហ្នឹង គ្រាប់ផ្លោងគេបាញ់ទៅរត់អាគាត់អាគាយ ។

ហៀង ៖ កាលហ្នឹងមីងមានពោះប៉ុន្មានខែហើយ?

ទឹម ៖ ពោះធំហ្នឹងជិតគ្រប់ខែដែរហើយ ។

ហៀង ៖ ហើយមីងមិតទៅណាទៅ?

ទឹម ៖ មិតទៅនៅស្រុក១០៥ហ្នឹង ហើយឡើងទៅលើរហូត ។

ហៀង ៖ នៅព្រៃមែនមីង?

ទឹម ៖ នៅតាមព្រៃ ។

ហៀង ៖ ហើយមីងទៅជាមួយគ្រួសារមីងទេ?

ទឹម ៖ ទៅតាមគ្នានៅភូមិសុខមុខហ្នឹង ។

ហៀង ៖ ឃុំអីដែរមីង?

ទឹម ៖ ត្រាំកក់ ។

ហៀង ៖ ស្រុកត្រាំកក់ ។

ទឹម ៖ កាលកូនង៉ើតភ្លឺច្បាស់ឡើងទៅទៀត ម្ចាស់ផ្ទះគាត់ថាអូនឯងកុំទៅណាទៀត អូនឯងតែទៅទៀតស្លាប់ហើយ ហើយខ្ញុំថាខ្ញុំមិននៅជាមួយយាយឯងម្ចាស់ផ្ទះទេ ប្ដីខ្ញុំចេញទៅហើយ ហើយយាយឯងឲ្យខ្ញុំនៅមានតែងាប់ ដល់ហើយខ្ញុំអត់សុខចិត្តនៅម៉ែឪទៅអស់មានតែទៅតាម ខ្ញុំដើរផ្លោងទីងៗមានងាប់មានរស់មានរបួសអញ្ចឹងទៅ ។

ហៀង ៖ ហើយមីងទៅជាមួយអ្នកណាគេមីង?

ទឹម ៖ ទៅជាមួយគ្រួសារ ឪខ្ញុំហ្នឹង ។

ហៀង ៖ ឆែម ហ្នឹង?

ទឹម ៖ ចា៎!

ហៀង ៖ ជាមួយប្ដីមីងឈ្មោះ ឆែម ហ្នឹង?

ទឹម ៖ ហ្នឹងអើយ ។

ហៀង ៖ ហើយពេលទៅហ្នឹងពីណាគេជាអ្នករត់តាមផ្លូវទៅដែរមីង?

ទឹម ៖ ទៅតែទាំងអស់គ្នាហ្នឹង ។

ហៀង ៈ ប្រជាជនទៅដែរ?

ខឹម ៈ ទៅទាំងអស់ មិនបាច់ចាំកម្មាភិបាលប្រធានភូមិអីទេ រស់ផ្លូវរស់ដូចតែគ្នាហ្នឹង អាណាផ្ទោង ត្រូវងាប់ក៏ងាប់ អាណារស់ក៏រស់ទៅ ហើយខ្ញុំចេះតែបន់ថាត្រូវខ្ញុំមុនគេទៅ មានរទេះខ្លះ ដួងមកខ្ទាតផ្ទោងអញ្ចឹងណា៎ ចំៗរទេះយើងតែម្តង ។

ហៀង ៈ គ្រាប់ផ្ទោងហ្នឹង?

ខឹម ៈ ចា៎! គ្រាប់ផ្ទោង ។

ហៀង ៈ ពេលហ្នឹង៧៩មែនមីង?

ខឹម ៈ ហើយពេលកើតហើយភ្លាមខ្ញុំមិនដែលស្គាល់ទឹក ស្គាល់ប្រៃអីទេ ហូរឈាមពេញខ្លួនអាឡាក់ ហើយស្រេកទឹកជិតងាប់ ហើយខ្ញុំថាកុំធ្វើបាបខ្ញុំព្រោះខ្ញុំជៀសងាប់មិនរួចនោះទេ ឲ្យខ្ញុំងាប់ នៅម្ដុំហ្នឹងទៅមិនបាច់ទៅណាទេ ឪម៉ែខ្ញុំគាត់ដាក់ខ្ញុំចោលហើយស្រម៉ោចចោះពេញខ្លួនទាំង អស់ ហើយខាំចង់ងាប់ ដល់ហើយបងខ្ញុំចាប់ខ្ញុំបោះឡើងលើរទេះតើ ។

ហៀង ៈ បងណា?

ខឹម ៈ បងប្រុស បងប្រុសខ្ញុំមាន២នាក់ ចាប់ខ្ញុំបោះលើរទេះ ហើយខ្ញុំថាទុកឲ្យខ្ញុំងាប់នៅហ្នឹងទៅ បើគេរត់ទៅទៀតបងទៅហ្នឹងគេទៅ ។

ហៀង ៈ ហើយមីងរត់ទៅដល់ណាដែរមីង?

ខឹម ៈ បើនិយាយពីរឿងរត់ហ្នឹងវាវែងឆ្ងាយណាស់ ។

ហៀង ៈ និយាយទៅមីង?

ខឹម ៈ រត់ហ្នឹង គឺរត់ឡើងភ្នំអញ្ចឹងកូនហ្នឹងចេះតែសើចទៅណា៎ ។

ហៀង ៈ កូនប៉ុន្មានខែហើយមីង?

ខឹម ៈ កូនហ្នឹង៣-៨ខែហើយ ហើយចេះសើច ដល់ពេលចេះសើចអញ្ចឹងទៅប្ដីខ្ញុំក៏គាត់នៅជាមួយ គ្នាដែរណា៎ នៅជាមួយគ្នាចេះតែរត់អើយរត់ រត់ហ្នឹងទ័ពគេនាំផ្លូវទេណា៎ តាមរទេះហ្នឹងរត់ម ឡើងភ្នំអញ្ចឹងទៅ ដឹងភ្នំលាចហ្នឹងទេអូន នៅខេត្តពោធិ៍សាត់ហ្នឹង ។

ហៀង ៈ ហើយម៉េចទៀតមីង?

ខឹម ៈ ដល់ហ្នឹងអញ្ចេះ ដីយើងស្អីនៅខាងលិចភ្នំពេញនេះ ខ្លាដេញម៉ែខ្ញុំណា៎ហើយនឹងឪខ្ញុំដែរ ។

ហៀង ៈ សត្វខ្លា?

ខឹម ៖ ចា៎! ហើយពេលហ្នឹងខ្ញុំដូចជាលែងដឹងអីហើយ ដូចថាគ្មានសង្ឃឹមរស់កន្លែងណាបន្តិចសោះ ពេលហ្នឹងខ្លាដេញម៉ែខ្ញុំ ដល់ហើយម៉ែខ្ញុំថា ឪអាឪចាំអញផង! ខ្លាធំណាស់ដេញអញ ហើយ តិចខ្លាខាំ ហើយចាស់ៗគេចេះតែថាកូនដំបូងវាក្រអូបបានខ្លាដេញហ្នឹង ។

ហៀង ៖ ហើយអត់មានអីណា៎មីង?

ខឹម ៖ ទម្រាំមកដល់ហ្នឹងម៉ែខ្ញុំចង់ដាច់ខ្យល់ រឿងអីឈប់នាំតែងាប់ បើគេទៅៗនឹងគេទៅ ដល់ពេល នេះក៏គេយកយើងទៅបំបែកក្រុមទៀតហើយ បំបែកទៅភ្នំហ្នឹង ។

ហៀង ៖ ពីណាគេជាអ្នកយកមីងទៅបំបែកក្រុមហ្នឹង?

ខឹម ៖ តាមពួកកងទ័ពដែលយើងទៅហ្នឹង គេបំបែកដុំអញ្ចឹងណា៎ គេចែកជាក្រុមអញ្ចឹងទៅ ។

ហៀង ៖ មីងស្គាល់កងទ័ពហ្នឹងទេ?

ខឹម ៖ អត់ស្គាល់ទេ គេទៅភ្នំហ្នឹងខ្ញុំក៏ទៅហ្នឹងគេទៅ ខ្ញុំថាពួកយើងនៅតែជៀសងាប់មិនរួចដដែល ហ្នឹង បើដើរទៅឃើញមនុស្សងាប់តាមផ្លូវរាបអស់ហើយ ងាប់ទាំងគ្រួសារៗ ងាប់នៅលើ ដីហ្នឹងប្រហែលគ្នាជាង១០នាក់ ហើយពួកយើងដើរទៅមុខបន្តិចទៀត ហើយគេថាមិនបាច់ ទេព្រោះជៀសងាប់មិនរួចទេ នឹកឃើញអញ្ចឹងណា៎ ដើរទៅមុខទៅ ហើយអ្នកស្លាប់ហ្នឹងមិន ដឹងគេស្លាប់ដោយសារអី ឃើញតែមនុស្សស្លាប់ស្គូក តែមិនទាន់ហើមទាន់អីទេណា៎ ឃើញ ស្លាប់គឺពួកខ្ញុំភ័យ ហើយចេះតែទៅមុខទៀតដល់ហើយគេយកទៅដាក់ជាក្រុមទៀតទៅណា៎ ហើយទឹកអណ្តូងអីសុទ្ធតែចាក់សោរអត់ឲ្យយើងផឹកទេណា៎ ហើយដាច់ទឹកដាច់អីគ្មានទឹកផឹក ទេណា៎ ហើយខ្ញុំនឹកឃើញដំឡូងគេ ដល់ហើយទៅលួចងាប់ម៉េចងាប់ចុះ យកខោអាវទៅកួន ទៅគក់នៅកន្លែងទឹកអណ្តូង ដល់ហើយទៅឃើញដំឡូងគេហើយក៏ដកដំឡូងគេក្តោបយកមក ដល់ហើយផ្អើរឃើញអាមនុស្សគេវ៉ៃចោលដោយសារលួចគេហ្នឹង ថាភ័យខ្លាំងណាស់ភ័យ ឡើងញ័រជើង ហើយគេថាអន្ទុងហ្នឹងគេទុកវ៉ៃពួកយើងងាប់ចោលនៅហ្នឹង ។

ហៀង ៖ មានស្គាល់ឈ្មោះអីទេ?

ខឹម ៖ នៅស្រុកហ្នឹងគេថាឈ្មោះ ម៉ូង ភ្នំម៉ូងហ្នឹង ដល់ពេលដល់ម៉ូងហ្នឹងគេថាអន្ទុងគេទុកវ៉ៃពួក ដែលនាំទៅហ្នឹង ពួកម៉ាក្រុមខ្ញុំហ្នឹងនាំគ្នាទៅច្រើនណាស់ប្រជាជនហ្នឹង ដល់ហើយខ្ញុំនឹកឃើញ ថាបើហេវយ៉ាងហ្នឹងងាប់អីក៏ងាប់ចុះ ហើយពេលកំសៀវទឹកខ្ញុំដាំស្ងោរអីហើយ ដល់ពេល ស្ងោរហើយឪក៏ភ័យម៉ែក៏ភ័យ ហើយខ្ញុំថាម៉ែអើយហូបឲ្យឆ្អែតទៅណាម៉ែ ម៉ែឯងឡើងហូប ដំឡូងទៅ ដល់ហើយម៉ែខ្ញុំថាកូនអើយកូន កូនឯងឲ្យម៉ែស៊ីត្រង់ណាទៅ ដល់ហើយម៉ែក៏បាន ហូប ហើយឪខ្ញុំថាកូនឯងឃ្លានយ៉ាងហ្នឹងបើគេឃើញងាប់ហើយ ហើយខ្ញុំថាងាប់អីងាប់ទៅ

ព្រោះខ្ញុំលែងគិតផាប់ហើយ ហើយខ្ញុំថាទៀតខ្ញុំថា ឃើញគេជីកអន្ទុងជ្រៅៗណាស់ ប្រហែលជាគេទុកកប់ពួកយើងហើយ ដល់ហើយឪខ្ញុំគាត់ថាឯងនៅឲ្យស្ងៀមទៅ ជៀសផាប់មិនរួចទេ ដល់ពេលអញ្ចឹងរត់ចេញពីហ្នឹងទៀតទៅ ទៅអញ្ចឹងទៅនឹកឃើញខ្លួនឯងមិនសង្ឃឹមរស់ទេ ដល់ហើយឪខ្ញុំថាកូនអើយកូនយើងមិនដឹងផាប់រស់នៅកន្លែងណាទៀតទេ ។

ហៀង ៖ ចុះប្ដីមីងនៅកន្លែងណាមីង?

ទីម ៖ ប្ដីនៅជាមួយគ្នាទេ មិនអីទេ ។

ហៀង ៖ អញ្ចឹងនៅជាមួយគ្នាទេ?

ទីម ៖ ចាំ! នៅជាមួយគ្នា ហើយជិះរទេះទៅទៀតទៅ សំដៅទៅភ្នំលះបង់ អូនដែលឮគេហៅភ្នំលះបង់ទេ?

ហៀង ៖ នៅភូមិណាដែរមីង?

ទីម ៖ នៅលើភ្នំ កាលហ្នឹងគេទម្លាក់រថក្រោះ តែមិនដឹងរថក្រោះស្អី រថក្រោះដងទ័ពដង គេបាញ់គ្នា ដល់ពេលបាញ់អញ្ចឹងទៅពួកខ្មានហោះហ្នឹងវាទម្លាក់គ្រាប់កាំភ្លើងដូងដាំង ហើយខ្ញុំក៏រមៀលខ្លួនចុះពីលើរទេះ ដល់ពេលចុះពីលើរទេះយើងថាគេស្លាប់អស់ហើយ កាំភ្លើងនិយាយពីគ្រាប់បាចសាចក្រហមពេញហ្នឹង ដល់ហើយព្រាត់ប្រាស់បែកគ្នាត្រឹមហ្នឹងទៅបែកប្ដីបែកអីត្រឹមហ្នឹង អត់មានស្គាល់គេឯងទេ ។

ហៀង ៖ ហើយមីងបែកមកណាមីង?

ទីម ៖ បែកហ្នឹងរត់ទៅជាមួយគេទៅ ឡើងភ្នំទៀតទៅ ។

ហៀង ៖ ហើយគ្រួសារមីងទៅណា?

ទីម ៖ អត់មានដឹងសោះ ។

ហៀង ៖ ហើយឪពុកម្ដាយរបស់មីងក៏បែកគ្នាដែរ?

ទីម ៖ បែកគ្នាអស់ ដល់ពេលបែកចេញទៅខ្ញុំចេះតែទៅជាមួយគេទៅ ទៅតាមគេអញ្ចឹងទៅហក់ទឹកជាមួយគេផាប់ទាំងខ្សែៗ ហើយខ្ញុំនេះអស់សង្ឃឹមរស់ហើយ ។

ហៀង ៖ មានកូនដែរ?

ទីម ៖ កូនខ្លួនឯងមួយចងផ្ទក់រហូត ចងផ្ទក់ដាក់កន្សែងស្ពាយណាអូន ដាក់ស្ពាយកូនពីមុខអញ្ចឹងទៅខោអាវមានតែមួយកំប្លេរទេ ឡើងភ្នំចុះភ្នំអញ្ចឹងទៅគ្មានអីហូបទេ ដល់ពេលទៅដកដើមឈើហ្នឹង ដើមហ្នឹងដូចដើមខ្ទិះអញ្ចឹងណាំ ពេលឃើញគេស៊ីក៏ស៊ីហ្នឹងគេទៅ អូនអើយនិយាយពីជូរៗឡើងស៊ីអត់បាន ជូរជងរមាស់ជង ដល់ពេលស៊ីហើយងងុយដេក ហើយដេកលក់

ដល់ ពេលដេកលក់ឡានគេទៅអស់អាលីង ពួកទ័ពសុទ្ធ ទ័ពហ្នឹងគេអត់មានកូនមួយទេ គេបោះ ចោលអស់ហើយ ដល់ពេលគេឆ្លងទឹកជាន់ខ្សែព្រួទៅអញ្ចឹង ជាន់ខ្សែព្រួបានពាក់កណ្តាលគេបាញ់បេ៤០ ហើយកូនខ្ញុំយំពេក ដល់ពេលយំពេកគេថាយកកូនទៅបោះចោល ដល់ហើយខ្ញុំដាក់ចិត្តថាបោះកូនខ្ញុំចោលហើយណា៎ កូនហ្នឹងខ្ញុំដាក់ញាត់ដោះ កាលហ្នឹងមានដោះ ដល់ពេលយូៗទៅបាត់ដោះអស់អាលីង ចុះបើអត់បាយអត់ទឹកនោះ មានក្រម៉ាមួយ ក្រម៉ាដែលទុកស្ពាយវានោះ ឯងបើយំខ្លាំងពេកយកកន្សែងហ្នឹង លាញាត់មាត់វាហួងអាយ៉ាស់ត្រង់ ហ្នឹងអស់ហើយព្រោះវាយំពេក ដល់ពេលកូនហ្នឹងងាប់ខ្ញុំបោះចោលទៅៗ ដល់ពេលដែលខ្ញុំបោះចោលនៅដើមឈើអញ្ចឹង ខ្ញុំថាកូនឯងងាប់ហើយម៉ែចេញទៅទៀត ហើយកូនអើយ កូនយើងព្រាត់ប្រាស់អស់ហើយ បើអញ្ចឹងក៏ម៉ែងាប់កូនឯងងាប់ដែរ ដល់ពេលអញ្ចឹងគេដកដង្ហើមខកៗអញ្ចឹងមើលឃើញណា៎ មើលឃើញមិតទៅយកកូនមកវិញ គេទៅអស់ហើយគេឆ្លងទឹកទៅអស់ហើយ ខ្សែព្រួហ្នឹងវែងណាស់ ហើយគេទៅបាត់អស់ហើយ ដល់ពេលទៅទាន់ហ្នឹងគេ គេឡើងទៅផុតអស់អាលីង ដល់ពេលនេះទៅជួបទ័ពហ្នឹង ទ័ពហ្នឹងថាមិត្តនារីឯង កុំទៅណានៅជាមួយខ្ញុំទៅ ដល់ហើយខ្ញុំថាខ្ញុំមិននៅជាមួយពូឯងទេ បើនៅខ្លាចយួនតាមទាន់សម្លាប់ខ្ញុំអស់ហើយ ហើយសម្លាប់ទាំងអស់គ្នា ពូឯងការហើយធ្វើទ័ពខ្ញុំមិនទៅតាមទេ ក្រែងលគេអារកខ្ញុំ ខ្ញុំមិនទៅតាមទេខ្ញុំសុខចិត្តងាប់ ងាប់ណាងាប់ចុះៗ

ហៀង : ហើយមីងយកកូនមកវិញហើយមីង?

ខឹម : យកមកវិញហើយ ហើយស្ពាយកូនទៀតហើយ ដល់ស្ពាយកូនយាយមួយគាត់នៅក្នុងរោងអាហ្នឹងសុទ្ធតែមនុស្សងាប់ហើយ ស្លាប់ពេញទឹកពេញដី កន្លែងណាក៏ងាប់ដែរ ហើយកន្លែងណាក៏កូនងើតស្រែកដែរ ហើយសងខាងសចិញ្ចាចអស់ហើយសុទ្ធតែមនុស្សងាប់ មុនដំបូងខ្លាចមនុស្សងាប់ ដល់ពេលយូទៅអត់ខ្លាចងាប់ដូចតែគ្នាហ្នឹង គេមិនងាប់យើងមិនងាប់មិនដឹងស្មានម៉ានងាប់ ដល់ពេលដើរទៅអញ្ចឹងកូនខ្ញុំក៏អត់អីដែរ កូនខ្ញុំហ្នឹងរស់វិញហើយ កូនហ្នឹងគ្មានឲ្យអឹមដោះទេណា៎ ប៉ុន្តែខ្ញុំសំណាងបានពួកទ័ពឲ្យថ្នាំពេទ្យកុំអីក៏ខ្ញុំមិនរស់ដែរ ទ័ពហ្នឹងថាកូននាងឯងម៉េចក៏យំអីយំម្លេះនាង មកនេះមកខ្ញុំឲ្យថ្នាំពេទ្យ ហើយខ្ញុំថាពូអើយពូខ្ញុំគ្មានកម្លាំងទៅទេពូ បើឃើញកូនខ្ញុំយំពូឯងចុះមក កងទ័ពហ្នឹងក៏ថ្នាំខ្ញុំហើយដាក់សុទ្ធតែកំប៉ុងអញ្ចឹងណា៎ ពេលដែលឲ្យថ្នាំមកខ្ញុំវាឆ្ងល់ដែរ វៀតណាមមកផ្ទុះខ្ញុំវាឲ្យថ្នាំគ្រាប់ៗដូចគ្រោះក្រហមយើងអញ្ចឹង ឲ្យត្រាំដឹកនោះ ហើយអត់បាយក៏រស់ដែរនោះ ឲ្យខ្ញុំអាហ្នឹងហើយកូនខ្ញុំ

ក៏ដាក់ ខ្ញុំដាក់ក្នុងមាត់ខ្ញុំឲ្យរីកហើយកូនខ្ញុំជញ្ជក់ទឹកដោះ ដល់ពេលទៅដល់ស៊ីងមួយខ្ញុំរើសបានដបមួយប៉ុណ្ណឹងដាក់ទឹកទុកសម្រាប់កូនហ្នឹងផឹក ហើយគ្មានដែលបានស្អីស៊ីហ្នឹងគេទេអត់រាប់ខែលើឆ្នាំ ដល់ពេលអញ្ចឹងហើយអីហើយកូនហ្នឹងបានជញ្ជក់អាហ្នឹងអស់ទៅហើយថ្នាំហ្នឹងអស់អាលីង ដល់ពេលអស់អាលីងអញ្ចឹងទ័ពគេទៅបាញ់ ដូចថាបាញ់បានដំរីណា៎ ដំរីអាធំៗហ្នឹងណា៎ គេថាឲ្យទៅយកទៅ ដល់ពេលទៅយកចោលកូនហ្នឹងមួយថ្ងៃ អត់ដឹងថាកូនហ្នឹងនៅឯណាទេ ហើយមិនដឹងថាចោលកូននៅណា ដល់ពេលហើយទៅដើររកកូនហ្នឹង រកវាមិនឃើញទៀត ដល់ហើយចេះតែទៅតាមគេគ្នា៣នាក់ស្រីៗហ្នឹង អាហ្នឹងលែងគិតហើយ គិតចោលកូន ហើយទោះបីងាប់ក៏ដោយរស់ក៏ដោយ ហើយដើរហ្នឹងគ្មានស្អីទប់ទេ គ្មានសង្ឃឹមរស់ទេ ងាប់ក៏ងាប់ចុះ ដល់ពេលហើយអត់មានបានសាច់ដំរីហ្នឹងហូបទេ អត់បានម្ហូបទៅដងទឹកយកមកដឹកហ្នឹងក៏ឃើញអាសាច់ដំរីហ្នឹង ដូចអាចំហៀវខ្លាញ់ជ្រូកហ្នឹងគេបោះចោលពេញហ្នឹង ហើយក៏ដើរអាហ្នឹងយកមកហូប ស្អុយៗហ្នឹងនៅហូបបានប្រហែលជា៣ថ្ងៃកន្លែងដែលគេថាដំរីៗហ្នឹង ដល់ពេលបានសាច់ដំរីហ្នឹងបានរើសអាសាច់អាឡោកអាឡាក់ស្អុយយកទៅបោះចោលណា៎ ដើរស្រង់អាហ្នឹងយកមកស្ងោរហូប ស្ងោរហូបហើយចេះតែដេកហើយហើយមិនឃើញកូនវិញទេណា៎ ចោលកូនមួយយប់មួយថ្ងៃហើយអត់មានឃើញកូនទេ កូននៅក្រៀមស្រមោចរោមពេញហើយហ្នឹង ដល់ពេលហើយខ្ញុំឃើញមានក្មេងប្រដល់ពេលហើយខ្ញុំឃើញមានក្មេងប្រុសម្នាក់គេបានស្បែកដំរី ហើយគេថាបងស្រីៗខ្ញុំផ្ញើរស្បែកដំរីនឹងបងស្រីផង ដល់ហើយខ្ញុំនឹកឃើញថាអញបានស្បែកដំរីអញ្ចឹង អញអត់ឲ្យក្មេងហ្នឹងទេដល់ហើយយកស្បែកដំរីហ្នឹង យកទៅលាក់ចុះនឹកឃើញអត់មានអីហូបប៉ុន្មានថ្ងៃ ហើយយកមកផ្ញើអញ្ចឹង អញមិនបានស៊ី ដល់ហើយយកទៅលាក់នៅឆ្ងាយហើយកូនហ្នឹងវាយំអើយយំ គេថាបងស្រីអើយបងស្រីខ្ញុំកំពុងតែរកបានប៉ុណ្ណឹងផង បងឯងអាណិតខ្ញុំចែកឲ្យខ្ញុំវិញ មកខ្ញុំស្ងោរឆ្អិនឲ្យ បងឯងពាក់កណ្ដាល ហើយខ្ញុំថាអូនអើយអូនខ្ញុំដេកលក់ទៅមិនដឹងអ្នកណាយកទេ ឯងដាក់នៅត្រង់ណាគឺនៅត្រង់ហ្នឹងឯងរកទៅ ដល់ហើយវាយំអើយយំយំអស់ចិត្ត ដល់ហើយនឹកឃើញអាណិត តែបើឲ្យវាៗនឹងមិនកាត់ឲ្យខ្ញុំទេ ហើយកាត់ណាដាច់មានកាំបិតមកពីណា ដល់ហើយកូនហ្នឹងឈប់យំហើយខ្ញុំវាឃ្លានពេកក៏ស្ងោរ សុំឆ្នាំងគេស្ងោរ អញ្ចឹងខ្លួនអញកុំដេក ឃ្លានយ៉ាំងហ្នឹងជិតងាប់ហើយ ស្ងោរស្បែកដំរីហ្នឹងចុះ ដល់ពេលស្ងោរអូនអើយធំឡើងៗហើយស្អានតែខាំដាច់ ម៉ែអើយខាំទៅដូចថ្ម ដូចម៉ែថ្មខាំអត់ដាច់ ហើយអង្គុយយំអស់ចិត្តមកអង្គុយខាំវិញ ឯងបានដាច់បន្តិចព្រោះសាច់កន្លែងហ្នឹងវា

ផុយ ហើយហូបអត់ដាច់ក៏ហុតទឹកស្ងោរហ្នឹងវិញ ហើយឆ្អែតដេកលក់ហើយ ឲ្យតែអស់ កម្លាំងដឹងតែដេកលក់ហើយ ហើយគ្មានស្អីមួយគ្រាប់សោះ បានស្បែកដីរហ្នឹង ដេកលក់ ហើយ ស្ពាយ៣ថ្ងៃទៅណាក៏សុំឆ្នាំងគេស្ងោរដែរ ដល់ពេលស្ងោរហ្នឹងលែងបានចាប់ផ្ដើម ដើរទៀតហើយ ឃើញមាន ត្រពាំងហើយត្រពាំងនៅក្នុងស្រុកក្នុងភូមិហ្នឹងមិនដឹងមានតាំង ពីពេលណាមកផ្ទុះក្បឿងអញ្ចឹងដុតឆេះ មានជញ្ជីង មានដើមឈើ តែមិនដឹងដើមឈើស្អីទេ ហើយរវល់តែគេប្រានដួលព្រោះគ្មានកម្លាំងទប់ទេ អញ្ចឹងកុំទៅនៅជិតគេព្រោះបើនៅជិតគេ ប្រានងាប់ហើយ ២នាក់ម៉ែកូននោះ អញ្ចឹងទៅឈរឆ្ងាយ ចាំតែផ្លែឈើជ្រុះអាងទៅរើស ទៅរើសដែរចង់ដឹង ផ្លែឈើហ្នឹងវារសជាតិយ៉ាងម៉េច ថាផ្អែមសាច់ហ្នឹងផ្អែម ហើយឥឡូវ នៅស្រុកយើងក៏មិនដឹងមិនស្គាល់ថាផ្លែអី សាច់ហ្នឹងដូចសាច់ចាន់អញ្ចឹង គ្រាប់ប៉ុណ្ណឹងៗ ហើយសំបកខាងជ័រ ហើយផ្អែមអាណាផ្អែមៗ អាណាជូរៗស៊ីទៅសឹងតែចេញមកវិញ ដល់ពេលអញ្ចឹងរើស បានផ្លែហ្នឹង៧ក៏ទុកនៅក្នុងស្បោង ហើយក៏ដើរទៅរើសកាច់ ហើយ ដើរកាច់ត្រពាំង ហើយមានកម្លាំងណាទៅដើទប់ត្រពាំង កាច់ត្រពាំងមិនទាន់បាក់ផងយើង នេះដួលដឹងបាត់ហើយ ហើយដួលណា៎ចាក់ទីងចាក់ដីជ្រមុជទាំងកូនទាំងម៉ែ មិនដឹងដួលទេ ដល់ពេលដួលហើយអាគេ មកតាមក្រោយហ្នឹងគេប្រានធាក់ទម្លាក់ ចិត្តអាក្រក់ណាស់អ្នក ដែលមិតទៅជាមួយគ្នាហ្នឹង គ្មានអ្នកណាមួយចិត្តល្អទេ ដល់ពេលអញ្ចឹងទៅពាំងហ្នឹងមិនបាន ស្ងាត់ ហើយខ្ញុំដើររកទៀត ទៅហើយបានត្រពាំងហ្នឹងប៉ុណ្ណឹង ដល់ពេលហើយបានរស់ ហើយផ្លែហ្នឹង៧ហើយត្រពាំង៣ កង់ប៉ុណ្ណឹងវែងហ្នឹងក៏ដាក់នៅក្នុងសាក់កាដូ ឃើញថាជីវិត អញបានរស់វែងឆ្ងាយទៀតហើយ ទៅឃើញត្រាវអូនអើយត្រាវស្រុកគេប៉ុនៗសសរធាង ណា៎ ទៅកាត់បានធាងប៉ុណ្ណឹង៣ក៏ខ្ញុំសុំកំសៀវគេ ហើយគេដេកលក់អស់ហើយ ហើយ ពេលទៅសុំកំសៀវគេកំសៀវគេមានទឹក អញ្ចឹងក៏មិនដឹងធ្វើយ៉ាងម៉េចដែរ ភ្លើងកំពក់ភ្លើង កូនមួយឲ្យដេកនៅកំភ្នក់ភ្លើងទៅ ហើយខ្ញុំហ្នឹងក៏ទៅរាវរកទឹកដាន់ទក់ៗទឹក ភ្លើងកំបុិនកំភ្លួន ដើងហើយដើរទាល់តែអាលត់ភ្លើងភ្លឹប ដល់ពេលអាលត់ក៏ដើរមកស្ទង់ ហើយមិនដឹងដើរ ដល់ណាទេអាទឹកហ្នឹង ដល់ពេលហើយថាកូនអញបើសិនណាចូលភ្នក់ភ្លើងក៏ងាប់ កំពក់អញ្ចឹង ហើយមានស្អីទាមពេញខ្លួន មិនទាន់ដឹងថាស្អីទាមទេណា៎ ដល់ហើយមានដឹងថាឈ្លើងលើ គោកណា៎ ទាមហើយពេញខ្លួនកូនទាំងអស់ អញ្ចឹងបេះទាកហ្នឹងចេញហើយយកទៅដាក់នៅ លើភ្លើងហ្នឹងសិន ដល់ពេលហើយកំសៀវមានទឹកហើយធាងត្រាវហ្នឹងប៉ុនៗសសរ នឹក ឃើញថាធាងហ្នឹងវានៅទៀតណា៎ ស្ងោរឆ្អិន មួយឆ្នាំងហើយនឹកឃើញថាឃ្លានញ័រដៃញ័រ

ជើងហើយឈើមាននោះ ហើយមានស្វាបព្រា មានអំបិលណាហូប ពេញម៉ាកំសៀវហ្នឹង នឹកឃើញថាអញស៊ីឲ្យអស់ ហើយតាំងចិត្តថាស៊ីឲ្យអស់ឆ្កឹះម្ដងបន្តិចៗ ពោះទើបតែកូន ហើយម៉ែគ្មានទេពោះរួមអស់អាលីង រមាស់ណាស់ ធាងត្រាវអូនអើយរមាស់ណាស់ រមាស់រួញអណ្ដាតអស់អាលីង ដល់ហើយទម្លាក់ដេកម៉ែកូនដេកព្រាត់កូន ក្រែងអាហ្នឹងវា ត្រដាក់វាមិនរមាស់ ដល់ពេលដេកហើយបាត់រួញអណ្ដាត អស់អាលីង លែងដឹងរួញដឹង រមាស់អីអស់ហើយ អញ្ចឹងឡើងស៊ីហ្នឹងទៀត ដល់ពេលឡើង ស៊ីទៀតម៉ែកូនអើយលើស ដើម បាត់អណ្ដាតហ្នឹងទៀតហើយ បាត់អណ្ដាតហ្នឹងអាលីង ថា រមាស់នោះរមាស់ អាទឹក ធ្លាក់មកដល់ទ្រូងអេសទ្រូងហ្នឹងចង់អាយ៉ាស់ហើយ ដល់ពេលអញ្ចឹងហើយដេកលក់ហើយ ហើយមីមួយគេថាឯងឡើងទៅបានមើមត្រាវធំៗណាស់ យាយអើយយាយឯងមិនឲ្យខ្ញុំ ម៉េច ខ្ញុំហូប៣ថ្ងៃក៏អស់ដែរ ខ្ញុំទុកក្នុងស្បោងខ្ញុំ ដល់ហើយ គាត់ថាអត់ទេឯងស៊ីឲ្យហើយ ទៅយាយហ្នឹងគាត់ខ្លាចរមាស់គាត់ឲ្យខ្ញុំស៊ីមុន ហើយកូននោះ យាយហ្នឹងឲ្យថាយាយហ្នឹងចិត្ត អាក្រក់ម្លេះ ហូបមិនទាន់បាត់អណ្ដាតរួញផងឥលូវមកឲ្យស៊ីទៀត ហើយលើសអាដើមហ្នឹង ទៀត រួញអណ្ដាតលែងហើយ និយាយក៏អត់ចេញដែរអូនអើយ លេបលែងរួចហើយ រមាស់ណាស់ ហើយថាយាយអើយយាយឯងជួយខ្ញុំផង អាយ៉ាស់មាត់ខ្ញុំអាលីង ស្រែក ហៅណាឮគឺមិនឮទេ រួញពេញអណ្ដាតហ្នឹងទាំងអស់ដេក ហើយដល់ពេលទៅទៀតហើយ ទៅទៀតឮសូរពួកទ័ពហ្នឹង ថាក្រោយបាញ់ចោលហើយ ខ្ញុំអត់តាមអ្នកឯងទេកុំបាញ់ខ្ញុំ ហើយកាំភ្លើងគេថ្មីៗសេកាគេចេញថ្មីដំនាន់ថ្មី ហើយអាសារ ក្រោយហ្នឹងនិយាយពីដាក់រ៉ាវ ដាំងៗ បើថាជីវិតត្រូវឲ្យងាប់ក៏ងាប់ទៅចុះ ហើយអត់មានខ្លាចងាប់ទេ ហើយក៏អត់ងាប់ ដែរ ឯងតែបាញ់ខ្លាំងអញកើបហើយដុំថ្មប៉ុនៗផ្ទុះបាញ់មកកើបៗបីបង់ រត់ឡើងទៅទៀត ដីរីព្រៃហ្នឹងបូតស្លឹកប្ញស្សី ហើយខ្ញុំថាអ៊ំដីរីអើយជាន់ឲ្យងាប់ទៅ មិនដីរីព្រៃដីរីស្រុកទ័ពនោះ នែ៊អាហ្នឹងធ្លាក់ស្ទឹងហើយ ដល់ពេលធ្លាក់ស្ទឹងខោមួយសំពត់មួយ ថ្ងៃណាទេស្លៀកខោខ្លី ព្រោះវារបូតសំពត់វានៅខោខ្លីទៅជាប់ស្ទឹង មនុស្សហូរនៅក្នុងស្ទឹងទាំងខ្សែៗ ហើយខ្ញុំហ្នឹង ក៏ងាប់ដែរ អណ្ដែតបាសដៃបាសជើងហើយហ្នឹង ព្រោះអីមាន ឆ័ត្រយោងមួយវាមាន ជាតិកៅស៊ូវាប៉ោងនោះ ខ្ញុំកន្ត្រាក់ជាប់រាបហើយហ្នឹង ហើយស្ទឹងហ្នឹងវាជាប់ជាមួយដើម ឈើទឹកហ្នឹងត្រឹមហ្នឹងៗ លែងមិនត្រឹមហ្នឹងទេហូរគ្លួចសត្វ អាសត្វ មនុស្សងាប់ទាំងខ្សែ ហើយថាអ៊ំអញងាប់ហើយ ងាប់ចុះងាប់ជាមួយម៉ែហើយនឹងកូនជាប់សំពត់ជាមួយឈើហ្នឹង កន្ត្រាក់ទម្រាំតែរួច ហើយអាកូននៅក្នុងថ្នក់ហ្នឹងងាប់ហើយ ដល់ពេល អញ្ចឹងហើយនៅ

ខោខ្ញីមួយហ្នឹង ហើយគាត់ហ្នឹងបាញ់ប្រាវៗជួបដីរីទៀតហើយ ដល់ពេល មកជួបដីរីមីមួយ នោះគេស្គាល់ខ្ញុំហើយគេថា អ៊ីឯងកើតអីបានជាហូរឈាមខ្លាំងម្ល៉េះ ហើយខ្ញុំថាខ្ញុំឈាមអី ខ្ញុំមិនដឹងផងហ្នឹង ដល់ហើយគាត់ថាអ៊ីឯងមើលហូរនោះ ប្រហែលជាអញត្រូវ គ្រាប់ហើយ ហើយគាត់ថាត្រូវណាបានឈាមម្ល៉េះ ដល់ហើយស្ទាបខ្លួនសព្វសាច់ហើយថា អញត្រូវ គ្រាប់កន្លែងណាបានជាមិនឈឺអញ្ចឹង ហើយអ៊ីហ្នឹងថាអ៊ីឯងមើលបាតជើងអ៊ីឯង ឈាម អ៊ីឯងមើលទៅហូរម៉ាំណាស់ ហូរពីហ្នឹងទៅដល់ហ្នឹង ហូរឈាមមកទាំងអស់ហ្នឹង ។

ហៀង : ត្រូវកន្លែងណា?

ខឹម : គ្មានត្រូវគ្រាប់ទេ ទាមអូនអើយ ហើយគ្មានខ្លួនទេ ណែនទាំងអស់ណែនពេញខ្លួនទាំងអស់ គ្មាននៅសល់កន្លែងណាទេ ខ្ញុំមិនទៅបុកដើមឈើ ឲ្យយកដើមឈើហ្នឹងចេញទាំងអស់ ហើយឈាមហូរនោះហូរ ទាំងម៉ែទាំងកូនហូរ ហើយថាចុះអញម៉េចអញ្ចឹងបើត្រូវគ្រាប់ម៉េច ក៏មិនឈឺ ហូរមកពីណាអាទាកហ្នឹង នៅតែថាឈ្លើងលើគោក ហើយយាយហ្នឹងគាត់ថា អញ្ចឹងៗពេញខ្លួនទាំងអស់ ដល់ពេលអញ្ចឹងហើយលែងខ្លាចទាកហើយ ដីរីគេភោចដៃមក ជាន់ផាប់ចុះ ហើយគេប្រាប់ថានារីមិនមែនដីរីព្រៃទេគឺដីរីស្រុក នារីឯងម៉េចអញ្ចឹង ហើយខ្ញុំ ថាខ្ញុំងើបពីទឹក ហើយកូនហ្នឹងបាត់ដង្ហើមហើយហ្នឹង ហើយខ្ញុំថាកូនខ្ញុំផាប់ហើយហ្នឹងពូ ដល់ ពេលរកបោះចោលកូនហ្នឹងដកសង្ការមាន់ ដល់ហើយស្ពាយកូនហ្នឹងទៀតហើយ ហើយខោ ហ្នឹងនៅតែហូរឈាមមួយថ្ងៃនៅតែហូរឈាមអត់ឈប់ ដល់ហើយមកឃើញមនុស្ស ហើយ ចាប់ផ្តើមនឹកឃើញមនុស្សផាប់ទៀតហើយ ខ្ញុំលែងខ្លាចផាប់ហើយ បើផាប់ក៏ផាប់ទៅ ដល់ ពេលអញ្ចឹងចាប់ផ្តើមទៀតហើយ គេអារមនុស្សរស់ ពូម្នាក់ហ្នឹងអារមនុស្សរស់ ហើយអារ ហ្នឹងក្មេងប្រុសល្អម ហើយអារហ្នឹងបើខ្ញុំសុំគេហូបសាច់មនុស្សហ្នឹងយ៉ាងម៉េចទៅអូន ពូ អើយខ្ញុំសុំម្ដុំមកព្រោះខ្ញុំឃ្លានម៉ាំណាស់ ដល់ហើយអត់ឲ្យ ពូអើយពូឯងបានច្រើនណាស់ខ្ញុំ សុំម្ដុំមកអត់ឲ្យចិត្តអាក្រក់ រកកាំបិតមកផារកាប់យើងទៀតណា ហើយចេញពីពូហ្នឹងហើយ ណា ។

ហៀង : ញ៉ាំសាច់មនុស្ស?

ខឹម : សាច់មនុស្ស ហើយខ្ញុំថាពូអើយខ្ញុំសុំមកព្រោះខ្ញុំជៀសផាប់មិនរួចទេ ហើយខ្ញុំថាសុំស៊ីដែរ មកឲ្យផាប់ទាំងអស់គ្នាទៅ ពូហ្នឹងអត់ឲ្យ ដល់ពេលអត់ឲ្យអាហ្នឹងមកជួបវៀតណាមហើយណា ហើយវៀតណាមស្អាតៗណាស់ ដូចថាសុទ្ធតែពួកហាណូយណា ហើយមិនចេះខ្មែរទេ ខ្ញុំទៅ ម្ហូមវា វាក៏ឲ្យបាយដូចអង្ករលីងអញ្ចឹង ចាក់ទឹកស៊ីអ៊ីវឲ្យមកហើយឲ្យនំប៉័ង មកដល់ពេល

ហ្នឹងយួនចាប់យើងវិញបានហើយ ដល់ពេលហើយយួនចាប់បានហើយ ទៅវ៉ៃអាមួយអារសាច់មនុស្សហ្នឹងស្លាប់ ដល់ហើយវៀតណាមវ៉ៃ វាពេញស្បៀង ដល់ពេលអញ្ចឹងវៀតណាមនាំឲ្យអង្ករឲ្យអី ហើយខ្ញុំហ្នឹងនឹកឃើញត្រពាំងអញនៅធំៗវៀតណាមឲ្យ ដល់ពេលឲ្យអញ្ចឹងនឹកឃើញអង្ករមួយកំប៉ុងប៉ុណ្ណឹង ហើយអាខ្លះឲ្យ អាខ្លះទៀតបេះខ្ទេះតិចឲ្យវាធ្វើដៃអញ្ចឹងណា៎ ឲ្យយើងស៊ីឥលូវឲ្យអស់ គេបបរស៊ីហើយផ្អែតដេកលក់នៅតែខ្ញុំម៉ាកំសៀវប៉ុណ្ណឹងខ្ញុំបបរមួយកំប៉ុងទាំងអស់ អាកំសៀវខ្ញុំធំប៉ុណ្ណឹងពេញ ហើយដាំងប៉ុណ្ណឹងមិនដឹងពុលឬក៏ម៉េច មិនដែលបានស្គាល់ជាតិបាយមួយគ្រាប់ក្នុងពោះទេ ស្រាប់ដល់ពេលហូបហើយអូនអើយភ្នំហ្នឹងវិលបុកដូចឡានដែលយើងជិះវើវៗហ្នឹងអញ្ចឹង ហើយខ្ញុំថាអញស្លាប់ហើយ ជៀសរកកន្លែងស្លាប់មិនរួច ហើយបបរហ្នឹងលឿងលើសអាមៀតទៀត ហើយត្រពាំងហ្នឹងបបរអាវីងដូចយើងបុករមៀតដាក់អញ្ចឹង ហើយកំសៀវប៉ុណ្ណឹង ហូបទាល់តែអស់ណា៎ មិនដែលបានបាយហូបផ្អែតទេណា៎ ស្រាប់តែញើសដូចភ្នំវិលមកបុកយើងអញ្ចឹងណា៎ ខ្ញុំថាខ្ញុំទៅរកកន្លែងស្លាប់ហើយ ដល់ហើយមានក្មេងៗ២នាក់ធំៗ ២ហ្នឹងជាអ្នកនាំផ្លូវពួកទ័ពទៅហ្នឹងហើយវាយំនៅចុងជើងខ្ញុំ វាថាបងស្រីៗ បងស្រីឯងឡើងទៅព្រោះគេទៅអស់ហើយ ហើយខ្ញុំថាខ្ញុំមិនទៅទេព្រោះខ្ញុំស្លាប់ហើយ ខ្ញុំពិបាកណាស់អូនអើយ ឯងកុំហៅពិបាកណាស់ ជៀសស្លាប់មិនរួចទេ ហើយខ្ញុំមានឈរនឹងណា៎ដេកហ្នឹង ដល់ពេលដេកយូទៅហើយ មានកម្លាំងក៏គេទៅស្ងាត់អស់អាលីង ហើយអា២នាក់ហ្នឹងនៅយំចុងជើងខ្ញុំនេះ ។

ហៀង : ម៉េចបានជាគេយំអញ្ចឹង?

ខិម : វាខ្លាចយួនវ៉ៃវាចោល វាប្រុសៗហ្នឹងហើយក្មេងៗ វាបងអើយបងឯងឡើងទៅខ្ញុំជួយយួកូន ខ្ញុំថាពេលដែលឯងមានអង្ករមានបាយស៊ីអញសុំតែបន្តិចឯងមិនឲ្យអញផង ឥលូវឯងឲ្យអញធ្វើអីបើវៀតណាមឲ្យអញហើយហ្នឹង ឯងមិនបាច់ឲ្យអញទេ គេឲ្យបាយមួយដុំនោះហើយខ្ញុំថាអត់យកទេ ឯងចិត្តអាក្រក់ណាស់ ដល់ពេលចិត្តអាក្រក់ណាស់វាអត់ឲ្យយើងហើយខ្ញុំក៏មិនឲ្យតាមដែរ វាចិត្តអាក្រក់ ប្រហែលជាពួកទ័ពហ្នឹង ពួកដែលនាំទៅហ្នឹងសុទ្ធតែពួកចិត្តអាក្រក់ ដល់ពេលអញ្ចឹងខ្ញុំបោះកូនខ្ញុំចោលទៅ បើមិនបោះខ្ញុំមានកម្លាំងណាទៅដាច់បាយដាច់ទឹក ហើយវៀតណាមហៅទៅមិនដឹងប៉ុន្មានថ្ងៃប៉ុន្មានខែបានមកដល់ គ្មានកម្លាំង គ្មានកំហែងបន្តិចទេ ។

ហៀង : មកដល់ណាមីង?

ទីម : វាចេះតែនាំៗ ហើយមកដល់ពោធិ៍សាត់វិញ មកដល់លាចខេត្តពោធិ៍សាត់ហ្នឹង ហើយចុះមកហ្នឹងវិញតាមផ្លូវហ្នឹង ដល់ពេលអញ្ចឹងមានអ្នកដកដំឡូងដកអី ហើយខ្ញុំហ្នឹងក៏ ដូចថាយើងដើរ អញ្ចឹងក៏មានចិត្តធម៌ ហើយអាថ្នាំពេទ្យនៅក្នុងកំប៉ុងហ្នឹងថាថ្នាំបំបាត់រាគ ឃើញពូមួយដេកស្តូកនៅតាមផ្លូវ ហើយប្តីប្រពន្ធស្លាប់នៅក្បែផ្លូវ ហើយថាអ៊ីៗកូនខ្ញុំបានដំឡូងមកហើយ ខ្ញុំសុំដំឡូងមួយមក ខ្ញុំដាច់បាយដាច់ទឹកអ៊ីឯងមេត្តាខ្ញុំផង ហើយខ្ញុំថាប្តីខ្ញុំស៊ីដំឡូងរាគមាំណាស់ អ៊ីឯងចង់បានមិនអីទេ ហើយខ្ញុំថាឲ្យតែអ៊ីឯងឲ្យខ្ញុំមកដំឡូងហ្នឹងខ្ញុំឲ្យគេ ហើយពូហ្នឹងលេបជា តើដល់ពេលជាទៅឲ្យដំឡូងខ្ញុំប៉ុនកដៃ ហើយថាស៊ីដំឡូងដឹកទឹក និយាយពីពោះហ្នឹងធំហើមគ្មានបន្ទន់ទេ ហើយគ្មានទេឯងទៅណាទៅទៅ រាគនោះរាគគ្មានបន្ទន់ ស៊ីដំឡូងហ្នឹងដូចដំឡូងហ្នឹងពុលម៉េចទេ រាគយ៉ាងហ្នឹង រាគហ្នឹងរាគថាស្លាប់ហ្មង ដល់ពេលអញ្ចឹងហើយកងទ័ព យើងចាប់ឆែកចាប់អីយើង ថាក្រែងលយើងមានលាក់មានអីនៅក្នុងខ្លួន ហើយខ្ញុំថាពូអើយកុំឆែកខ្ញុំអី ព្រោះខ្ញុំគ្មានកម្លាំងឡើងឲ្យពូឯងឆែកនោះទេ កូនខ្ញុំអាចម៍ប្រូចពេញមាត់ អាទ័ពដែលឆែក ពួកខ្ញុំហ្នឹង ប្រូចមកអាកូនហ្នឹងវារាគដែរ ។

ហៀង : ក្រែងមីងបោះចោល?

ទីម : បោះចោលហើយយកមកវិញទៀត កូនហ្នឹងនៅតែយកអញ្ចឹង ទោះបីស្លាប់ហើយនៅតែយកអញ្ចឹង យកហ្នឹងយាយហ្នឹងថាអញ្ចេះ មីងនាង! មីងនាងឯងកុំចោលកូនណ៎ា កូននាងឯងមានព្រេងមានសំណាងណាស់ ឯងមើលទៅកូនឯងទៅ កូនឯងមានបុណ្យស័ក្ត យាយហ្នឹងគាត់ចេះតែថាអញ្ចឹង ហើយខ្ញុំនឹកឃើញថាយាយហ្នឹងចេះបំភ្លឺអញមួយដែរ ឲ្យតែបោះចោលដឹងតែនឹកឃើញយាយហ្នឹងនិយាយថាកូនហ្នឹងមានបុណ្យ យាយហ្នឹងចៅ៥-៦នាក់ ជៀសស្លាប់មិនរួចមានស្អីស៊ី ហើយយាយហ្នឹងថានៅជាមួយអញទៅ ហើយខ្ញុំថានៅជាមួយយាយឯងបានស្អីហូប បើយាយឯងស្លាប់ខ្ញុំក៏ស្លាប់ដូចគ្នា ហើយអាដើមឈើក្នុងភ្នំអូនអើយ គល់ដល់ចុងឫសវាហ្នឹងផ្អែប៉ុណ្ណឹងៗ ផ្អែមណាស់ បើបានទៅបេះទាន់គេក៏ទាន់ អាណាមិនទាន់ គេប្រានចោលហ្នឹងដួលនៅហ្នឹងទៅ មិនដែលបានហូបស្រួលទេ វេទនាណាស់ ។

ហៀង : ចុះមីង២នាក់នោះមានទៅជាមួយមីងទេ?

ទីម : អានារសា២នាក់ហ្នឹងទៅ ។

ហៀង : ទៅតាមមីង?

ទីម : ទៅតាមខ្ញុំ តាមទៅទាល់តែចេញមកវិញ ហើយវាថាបងឯងកុំទៅស្រុកទៅភូមិ នៅជាមួយខ្ញុំទៅខ្ញុំចិញ្ចឹមបងឯង នៅខាងខេត្តពោធិ៍សាត់ ហើយវាថាអញ្ចេះទៀតណា វាថាបងឯង

នៅជាមួយខ្ញុំទៅព្រោះខ្ញុំមានកប់កំណប់ទុកច្រើនណាស់ ហើយខ្ញុំថាអញមិនជឿឯងទេ ពួកឯងដូចចង់សាប់អញ្ចឹងហើយមិនចង់សាប់ទេ ឯងគ្មានទៅចិញ្ចឹមអញទេ អញមិនទៅទេអញទៅ ស្រុកអញហើយ ហើយខ្ញុំមកស្រុកខ្ញុំមក ។

ហៀង : កូនមីងនៅរស់ទេ?

ទឹម : កូនហ្នឹងនៅរស់ដល់សព្វថ្ងៃ ហើយកូនហ្នឹងនៅរស់ឥលូវគេមាឌធំធាត់ណាស់ គេស៊ីបានអីបាន ហើយគេថាម៉ែអើយម៉ែឯងមិនដឹងច្រើកូនរាជវង្សណា ម៉ែឯងបោះខ្ញុំចោលក៏មិនដឹងហើយខ្ញុំចេះតែសើចទៅ ហើយគេថាមិនដឹងរើសបានកូនរាជវង្សណាទេ មានព្រេងមានសំណាងហើយ ។

ហៀង : កូនហ្នឹងសំណាងមែនទែនហ្នងមីង?

ទឹម : ហើយនិយាយប្រាប់ម៉ែខ្ញុំ ម៉ែខ្ញុំយំ ហើយខ្ញុំនិយាយកាលពេលនោះខ្ញុំនិយាយប្រាប់ម៉ែឪខ្ញុំពេលម៉ែខ្ញុំយំខ្ញុំក៏យំ បងប្អូនខ្ញុំឲ្យតែខ្ញុំទៅភ្នំពេញម្តងៗគេចតទុកហើយស្តាប់យំទាំងអស់គ្នាហើយគាត់ចុះឯងម៉េចក៏វេទនាម្លេះ ។

ហៀង : ហើយចុះមីងប៉ុន្មានខែប៉ុន្មានឆ្នាំបានមកដល់ស្រុក?

ទឹម : មិនដឹងប៉ុន្មានខែប៉ុន្មានឆ្នាំ នៅលើភ្នំហ្នឹងដើររហូត ។

ហៀង : ដើរមកនៅភូមិនេះវិញ?

ទឹម : ចា៎! មកនៅភូមិហ្នឹង ។

ហៀង : មកនៅភូមិត្រាពាំងវន្ធហ្នឹង?

ទឹម : ចា៎!

ហៀង : មីងមកជួបគ្រួសាររបស់មីងទេ?

ទឹម : មកជួបជុំវិញ ។

ហៀង : ហើយចុះ តាឆែម ហ្នឹងម៉េចវិញ?

ទឹម : តាឆែម មានអីមកជួបគ្នា ប្តីប្រពន្ធខ្ញុំមិនដែលឈ្លោះគ្នាទាល់តែឥលូវហ្នឹង ចេះតែសុខរដុមរម្យនា ចេះតែរកស៊ី ហើយកាលពីមុនយើងព្រាត់ប្រាស់គ្នា បែកគ្នាមិនសមបានរស់នៅជាមួយគ្នាទេ ខ្ញុំនឹកឃើញថាជីវិតខ្ញុំពេលហ្នឹងអញរកស៊ីបានប៉ុន្មាន អញអត់មានយកទុកទៅមុខទៀតទេ រកបានប៉ុន្មានអញស៊ីឲ្យឆ្អែត ពេលនោះអញសាប់អត់មានសល់អីប៉ុនចង្កឹះទេ ព្រាត់ប្រាស់ឪខ្ញុំ ហើយគាត់មកស្លាប់នៅពោធិ៍សាត់ហ្នឹង ព្រោះអត់មានបាយមានទឹក បានអ្នក

មួយគេឆ្ងល់ថា ឯងដឹងឪឯងស្លាប់ទេ គាត់ស្លាប់ពេលដែលបែកហ្នឹង ហើយស្លាប់នៅខាងជើងភ្នំលាចហ្នឹង ហើយខ្ញុំថាអត់ដឹងទេ ។

ហៀង ៖ ចុះម្តាយមីងនៅជាមួយមីងមែនទេ?

ទីម ៖ ម្តាយមកនៅជាមួយខ្ញុំ ហើយម្តាយទើបតែស្លាប់ប្រហែលជា៣ឆ្នាំ ។

ហៀង ៖ អញ្ចឹងមីងសំណាងល្អមែនទែន?

ទីម ៖ សំណាងនោះថាសំណាង ជីវិតខ្ញុំថាគ្មានរស់ទេ ។

ហៀង ៖ តាំងពីឈឺងទាម ។

ទីម ៖ អាឈើងទាមខ្ញុំថាមិនមែនទាកទេ ប្រហែលជាឈើងហើយ បើមិនអញ្ចឹងទេគឺភ្លើងលើគោកហើយ ហើយអាពេលឡើងភ្នំកូនហុចទៅគ្នាម្តងម្នាក់អូនអើយ ថ្មសុទ្ធតែលុតជន្លង់វា ហើយសិនណាជាធ្លាក់រូងមានសេះមានមនុស្សងាប់ពេញអន្លង់ ដូចថាវាសំណាង ជួនកាលយើងដើរឆ្លងស្ទឹងអូរហ្នឹង ឃ្វានគ្មានពេលយប់ដឹងថ្ងៃ ។

ហៀង ៖ ចុះពេលដែលមីងមកដល់ហ្នឹងវិញអត់មានបញ្ហាអីទេ?

ទីម ៖ អត់មានបញ្ហាអីទេ ។

ហៀង ៖ រស់នៅសុខស្រួលទេ?

ទីម ៖ រស់នៅសុខដុមរម្យនាទេ ចេះតែរកស៊ីចិញ្ចឹមកូនអញ្ចឹងណា កូននៅ៦នាក់រាល់ថ្ងៃហ្នឹង ។

ហៀង ៖ ហើយប្តីមីងគាត់អត់មានចែករំលែកមីងរឿងគាត់បែកទៅណាទៅណីទេ?

ទីម ៖ គេសុខដុមរម្យនាជាមួយម៉ែឪគេទៅ គេស្លាប់ចោលអញ្ចឹងទៅ ហើយគេមានរទេះមានគោអីគេមានព្រាត់ប្រាស់ណា៎ វេទនាតែខ្ញុំហ្នឹង ហើយដល់ពេលហ្នឹងមនុស្សគេដាក់ចោលហ្នឹងសាក់កាដូខោអាវគេចោលដូចភ្នំ ទៅតាមទៅគេថាឯងទៅតាមចោលកូនទៅ ហើយខ្ញុំថាខ្ញុំមិនចោលទេកូន ហើយគេថាឯងទៅ ឆ្លងទៅក្រៅប្រទេស កាលហ្នឹងគេចាំមកយកតើខ្ញុំអត់ដឹង ឃើញទឹកហើយចោលកូនច្រើនពេក ខ្ញុំស្តាយកូន ចោលគដូចភ្នំ ហើយគេបាញ់ខ្ញុំហើយ ពេលបាញ់ខ្ញុំក្រាប កាំភ្លើងដាក់សុទ្ធបេហើយបាញ់ខ្ញុំខ្ទាត អញ្ចឹងបានថាជីវិតខ្ញុំវាវែងឆ្ងាយណាស់ ដូចអ្នកពោះធំធ្វើបាបគេ គេធ្វើបាបវិញ ហើយខ្ញុំអត់មានធ្វើបាបគេទេខ្ញុំសានតែ អំពើល្អក៏បានបុណ្យហើយឃើញទេ អ្នកពោះធំមិនតិចគេធ្វើបាបនៅកន្លែងពេទ្យហ្នឹង ហើយគាត់នៅដឹងគុណខ្ញុំដល់ឥលូវហ្នឹង គាត់ថាកូនអើយកូន កូនឯងកើតមកនៅពេទ្យគេចិត្តល្អណាស់ ក្រៅពីហ្នឹងសុទ្ធតែចិត្តអាក្រក់ ហើយអ៊ីមួយហ្នឹងអូនឯងសួរគាត់មើលគាត់ស្រលាញ់ ខ្ញុំណាស់ គាត់នៅតែរាប់ខ្ញុំអញ្ចឹង ។

ហៀង ៖ អរគុណមីងច្រើនហើយ ហើយជីវិតរបស់មីងនេះកំសត់ណាស់ ។

ខឹម ៖ កំសត់ណាស់ ជីវិតខ្ញុំនេះគ្មានសង្ឃឹមរស់នោះទេ ដូចខ្ញុំប្រាប់អូនឯងអញ្ចឹង ពេលហ្នឹងទោះបីជាមានស៊ីក៏មិនទុកដែរ មានប៉ុន្មានខ្ញុំស៊ីឲ្យអស់ ហើយខ្ញុំប្រាប់កូនខ្ញុំឃំណា៎ ខ្ញុំថាថ្ងៃណាមួយកូនឯងផតទុកទៅ ឯងស្ដាប់ដូចម៉ែនិយាយប្រាប់អញ្ចឹង ម៉ែឪខ្ញុំ បងប្អូនខ្ញុំឲ្យតែខ្ញុំនិយាយប្រាប់ដឹងតែឃំ ហើយខ្លួនខ្ញុំហ្នឹងមុនដំបូងមានខោស្មៀក ដល់ពេលឆ្លងដើមឈើប៉ុណ្ណឹងតែមួយថ្ងៃអាយ៉ាស់ខ្ទេក វាអាងមានខោក្នុងនោះ ហើយគ្មានខោស្មៀកទេ ភ្លៀងទាំងយប់ភ្លៀងទាំងថ្ងៃ ហើយកូនហ្នឹងអត់មានដាក់ដេកណាទេ គឺដាក់ដេកនៅប្រឡោះក្លៅហ្នឹង ហើយម៉ែគ្មានបាយហូបផង កូនហ្នឹងដេកនៅតែប្រឡោះក្លៅហ្នឹង ។

ហៀង ៖ កូនហ្នឹងមក?

ខឹម ៖ កូនហ្នឹងពីមុនមានតែសសៃហើយនឹងឆ្អឹងទេ

ឥលូវទៅមើលទៅកូនខ្ញុំអាហ្នឹងធំណាស់អូនអើយ ហើយសុខភាពវាដូចគ្មានអីឈឺសោះ ។

ហៀង ៖ ប្រហែលជាមីងជួយគេច្រើនអញ្ចឹង ហើយបុណ្យកុសលមកឲ្យកូនរបស់មីងវិញ ឈ្មើងទាមផងអីផងនៅតែរស់ ។

ខឹម ៖ ហើយបើនិយាយពីរឿងសត្វក្នុងទឹកគ្មានថ្ងៃរស់ទេ អាទាកទាមហ្នឹង ខ្ញុំថាអញម៉េញគេបាញ់ហើយ ហើយត្រូវត្រង់ណាក៏ឈឺនោះ តែឈាមហូរពេញខ្លួន ដល់ពេលទៅមើលទាកទាមគ្មានសល់សាច់ ហើយខ្ញុំមានដែលស្គាល់ទាកស្អីខ្ញុំ ស្គាល់តែឈ្មើងក្នុងទឹក ហើយព្រៃស្រុកគេ យប់ក៏គេអត់ឲ្យដើរដែរ យប់ឡើងភ្លឺដី ហើយអាណារលួយគូទ រលួយដៃនៅអាវើសអាវ៉ាស់ហ្នឹង គ្មានសល់សាច់ទេត្រូវប៉ះបារតហ្នឹង ហើយភ្លឺចិញ្ចាចក្នុងភូមិគេ ហើយខ្លួនខ្ញុំមកហ្នឹងមានសង្ឃឹមរស់តិចណាស់ រឿងអីមិនសង្ឃឹមរស់បើមានតែភ្នែកហើយនឹងខ្លួនហ្នឹង ស្គមតូច ហើយកូនហ្នឹងសឹងតែប៉ុនកដើង ហើយឥលូវទៅមើលកូនខ្ញុំមើលធំណាស់ ធំមែនទែននៅក្នុងខ្លួនវាដូចគ្មានកើតទុករឿងអីសោះ ។

ហៀង ៖ អញ្ចឹងមីងអរគុណមីងច្រើនហើយ ។

ខឹម ៖ ចា៎! មិនអីទេ ។

ទេវិទ្ធៈ ស្រុកនេះគេហៅស្រុកអី?

ខឹម ៖ ស្រុកនេះកាលជំនាន់ ប៉ុល ពត គេហៅស្រុក១០៩ ។

ទេវិទ្ធៈ តំបន់អីគេមីង?

ខឹម ៖ មិនដឹងតំបន់អីទេដឹងតែស្រុក១០៩ ។

ទេវិទ្ធៈ ដូចជាតំបន់១៣?

ទឹម ៈ ហ្នឹងអើយតំបន់១៣ ។

ទេវិទ្ធៈ ចៅហ្វាយស្រុក១០៩ពីណាគេមីង កាលដំបូង?

ទឹម ៈ មាន តាម៉ុក, តាទិន, តាតំ ។

ទេវិទ្ធៈ តាម៉ុក ហ្នឹងពីណាគេ?

ទឹម ៈ តាម៉ុក តាមួយគេយកទៅដាក់គុកកាលអាពតគេយកកាត់ទោសកាត់អីហ្នឹង ងាប់ក្នុងគុកហ្នឹង

ទេវិទ្ធៈ តា១៥ហ្នឹងមែន?

ទឹម ៈ ហ្នឹងអើយតា១៥ ។

ទេវិទ្ធៈ ចុះ តាម៉ុក ប្រធានភូមិភាគនារតីតើ?

ទឹម ៈ ចា៎! គាត់ប្រធានភូមិភាគ តាហ្នឹងកាលរត់ទៅលើភ្នំជួបគាត់តើ ទៅជួបគាត់ គាត់ទៅវៃទ័ព នៅលើភ្នំពេញទឹកពេញដី ហើយពួកខ្ញុំបរទេស ពួកទ័ពគាត់អត់បាយអត់ទឹកបាញ់គ្នាអាយ៉ អាយ៉ាពេញហ្នឹងមេទ័ពហ្នឹង ។

ទេវិទ្ធៈ ចុះមានពីណាគេទៀតមីង?

ទឹម ៈ តាទិត តាតំហ្នឹង ។

ទេវិទ្ធៈ មួយណាមុន?

ទឹម ៈ តាតំនៅមុន ហើយ តាទិតនៅក្រោយ ។

ទេវិទ្ធៈ តាតំ ហ្នឹងពីណាគេ?

ទឹម ៈ តាតំ ហ្នឹងគណៈស្រុកយើងហ្នឹង គាត់មកនៅកាន់នៅហ្នឹង ។

ទេវិទ្ធៈ គណៈស្រុកឬក៏គណៈតំបន់ ។

ទឹម ៈ គណៈតំបន់ហើយគាត់មកនៅហ្នឹង តាទិត ហ្នឹងនៅទេឥលូវ ។

ទេវិទ្ធៈ តាទិត គាត់នៅណា?

ទឹម ៈ គាត់នៅវត្តភ្នំនៅភ្នំពេញហ្នឹង ។

ទេវិទ្ធៈ នៅភ្នំពេញហ្នឹង?

ទឹម ៈ ចា៎! នៅភ្នំពេញ ។

ទេវិទ្ធៈ គាត់ចៅហ្វាយស្រុក១០៩?

ទឹម ៈ ហ្នឹងអើយ ។

ទេវិទ្ធៈ តាទិត ហ្នឹងត្រូវជាម៉េចនិង តាតំ?

ទឹម ៖ មិនដឹងអីដែរខ្មែរយេះគាត់ កាលហ្នឹងគាត់ធ្វើការយើងម៉េចនិងដឹងអូនៗ

ទេវិទ្ធ៖ អត់ស្គាល់ ហើយអត់មានជាប់សាច់ញាតិអីទេ?

ទឹម ៖ អត់មានជាប់សាច់ញាតិផងខ្ញុំម៉េចនិងដឹងៗ

ទេវិទ្ធ៖ គាត់ដែលចុះមកទេ ហើយដែលជួបគាត់ទេ?

ទឹម ៖ ពេលឥលូវមានគេអ្នកជួបៗ

ទេវិទ្ធ៖ តាទិត ហ្នឹង?

ទឹម ៖ តាទិត ហ្នឹងឥលូវគេជួបតើៗ

ទេវិទ្ធ៖ ចុះកាលពីសម័យជំបូងមានដែលជួបទេ?

ទឹម ៖ អីមិនជួបៗ

ទេវិទ្ធ៖ គាត់ជាមនុស្សយ៉ាងម៉េចដែរ?

ទឹម ៖ មនុស្សគាត់ល្អដែរណា៎ តាទិត តាតំ មនុស្សល្អដែរតើ គាត់មិនធ្វើបាបអ្នកស្រុកអ្នកភូមិទេៗ

ទេវិទ្ធ៖ តាទិត ហ្នឹងគាត់អ្នកស្រុកខាងណាដែរ?

ទឹម ៖ អ្នកស្រុកហ្នឹងសុទ្ធតែអ្នកស្រុកមកពីលើ មកពីស្រុក១០៥ៗ

ទេវិទ្ធ៖ ជួបគាត់ជួបពេលណាដែរ ហើយជួបញឹកញាប់ទេ?

ទឹម ៖ ជួបបច្ចុប្បន្ននេះមែនអូន?

ទេវិទ្ធ៖ អត់ទេ កាលសម័យខ្មែរក្រហម?

ទឹម ៖ កាលសម័យខ្មែរក្រហមជួបគាត់ព្រឹកល្ងាចៗ

ទេវិទ្ធ៖ ជួបរាល់ថ្ងៃ?

ទឹម ៖ ចា៎! គាត់ចុះមកធ្វើការនៅហ្នឹងៗ

ទេវិទ្ធ៖ ធ្វើការនៅណាអ៊ំ?

ទឹម ៖ ធ្វើការនៅឃុំហ្នឹង ឃុំរាមអណ្ដើកហ្នឹងៗ

ទេវិទ្ធ៖ គាត់ចុះមកដល់ឃុំហ្នង?

ទឹម ៖ ចា៎!

ទេវិទ្ធ៖ គាត់មកមើលអីគេ?

ទឹម ៖ គាត់ទទួលខុសត្រូវតាមឃុំតាមភូមិ ពួកទ័ពពួកអីហ្នឹងៗ

ទេវិទ្ធ៖ ហើយពេលគាត់ចុះមកយ៉ាងម៉េចដែរ ហើយចុះមកហ្នឹងមានអ្នកណាគេខ្លះ?

ទឹម ៖ មកហ្នឹងមានតែគាត់ហើយនឹងនារសារបស់គាត់ហ្នឹង ។

ទេវិទ្ធៈ នារសាគាត់ប៉ុន្មាននាក់ដែរអ៊ំ?

ទឹម ៖ មាន២នាក់ ។

ទេវិទ្ធៈ ឈ្មោះអីខ្លះ អ៊ំមានស្គាល់ទេ?

ទឹម ៖ ឈ្មោះ ចុង ។

ទេវិទ្ធៈ ហើយមួយទៀតឈ្មោះអីដែរ?

ទឹម ៖ អាមួយទៀតឈ្មោះអីទេភ្លេចបាត់ហើយ ។

ទេវិទ្ធៈ ឥលូវគាត់នៅណា២នាក់ហ្នឹង?

ទឹម ៖ មួយទៀតឈ្មោះ យ៉ន ហ្នឹងនៅស្រុក១០៥ ។

ទេវិទ្ធៈ ចុះ២នាក់ហ្នឹងគាត់នៅណាអ៊ំ?

ទឹម ៖ ២នាក់ហ្នឹងនៅឃុំព្រៃម្ទេង ហើយឈ្មោះ ចុង គាត់ធ្លាប់ជួប តាទិត ឥលូវដែរតើ ។

ទេវិទ្ធៈ បើសិនជាខ្ញុំចង់ទៅសម្ភាសន៍គាត់បានទេអ៊ំ?

ទឹម ៖ ចង់សម្ភាសន៍ ចុង ហ្នឹង?

ទេវិទ្ធៈ បាទ!

ទឹម ៖ ទៅបាន ។

ទេវិទ្ធៈ គាត់នៅភូមិអីគេ?

ទឹម ៖ ចុះយើងសម្ភាសន៍ការពិត មានទៅនិយាយអីរឿងកុហកបោកប្រាស់ យើងត្រឹមត្រូវយើងត្រង់ វាធ្វើបាបយើងម៉េចយើងនិយាយអញ្ចឹង ។

ទេវិទ្ធៈ ចុះគាត់ឈ្មោះអី ចុង?

ទឹម ៖ ឈ្មោះអី ចុង ទេគាត់ជាអ្នកស្រុក១០៥ ។

ទេវិទ្ធៈ នៅឃុំព្រៃម្ទេង?

ទឹម ៖ ចាំ!

ទេវិទ្ធៈ ចុះភូមិ?

ទឹម ៖ ភូមិព្រៃម្ទេង ទៅដល់ហ្នឹងនៅជិតវត្តព្រៃម្ទេងសួររកឈ្មោះ ចុង ទៅគេស្គាល់ហើយ គាត់ធ្លាប់ជាសិស្សជិតរបស់ តាទិត ហ្នឹង។ ហើយកាលជំនាន់ ប៉ុល ពត ហ្នឹងពេលដែលគេជម្លៀសទៅវ៉ៃចោលហ្នឹង ហើយខ្ញុំគេវាសវែងចេញ ហើយគេឃើញគេវ៉ៃចោលហ្នឹងអាណិតគេណាស់ ហើយកាលណាអាណិតគេគឺខ្លាចជីវិតរបស់ខ្លួនឯងមិននៅដែរ ។

ទេវិទ្ធៈ	វ៉ៃនៅណាដែរ?

ឹម ៈ	វ៉ៃចោលកាលជំនាន់ហ្នឹង គ្មានវ៉ៃចោលណាមានតែវ៉ៃនៅជិតហ្នឹង អាខ្លះឲ្យមាន អាខ្លះឲ្យអី ខ្ញុំបំរុងនាំពួក១៧វត់ពីរដង តែខ្លាចតែគេរត់មិនរួចគឺខ្ញុំរត់មិនរួចដែរហើយ កាលហ្នឹងខ្ញុំនៅដេរណា៎ ។

ទេវិទ្ធៈ	អ៊ំមានស្គាល់អ្នកណាធ្វើប្រធានទេ?

ឹម ៈ	ពួកប្រធានហ្នឹងស្លាប់អស់ហើយ ។

ទេវិទ្ធៈ	ប៉ុន្តែមានស្គាល់អ្នកណាទេ?

ឹម ៈ	ឈីម ហ្នឹងស្លាប់ហើយ ។

ទេវិទ្ធៈ	អត់មានអ្នកណានៅរស់ទេ?

ឹម ៈ	អត់មាននៅទេ ។

ទេវិទ្ធៈ	ក្រែងលមានអ្នកណាគេដឹងអញ្ចឹងណា៎?

ឹម ៈ	អត់មានទេ ស្លាប់អស់ហើយ ស្លាប់នៅខេត្តកំពត ។

ទេវិទ្ធៈ	ចុះបើចង់ដឹងពីរឿងពួកគាត់ប្រធានហ្នឹងទៅសួរអ្នកណាគេវិញ អ្នកដែលធ្លាប់ធ្វើការសម័យខ្មែរក្រហមណា៎ អ្នកដែលដឹងច្រើន អ្នកដែលធ្លាប់ធ្វើការក្នុងហ្នឹង គុកហ្នឹងគុកស្រុកឬក៏គុកអីណោះ?

ឹម ៈ	សួរច្រើន ចង់ដឹងខ្លាចគេខឹង សួរពូ ឈឿន ហ្នឹងគាត់នៅត្រពាំងរន្ទណា ហើយបើគាត់សួរថាអ្នកណាថាអត់ដឹងទេណា៎ ។

ទេវិទ្ធៈ	បាទ!

ឹម ៈ	អាហ្នឹងនាំគេស្អប់ ។

ទេវិទ្ធៈ	គាត់ឈ្មោះអី ឈឿន?

ឹម ៈ	មិនដឹងអី ឈឿន ទេ តែគាត់នៅក្នុងហ្នឹងដែរណា៎ គាត់ធ្វើការនៅហ្នឹង ខ្ញុំនិយាយប្រាប់ត្រង់ គាត់ហ្នឹងចិត្តអាក្រក់ណាស់ យើងដឹងរឿងគេច្រើនក៏វាមិនកើត ។

ទេវិទ្ធៈ	ផ្ទះនៅម្តុំណាមីង?

ឹម ៈ	ផ្ទះគេជិតនេះអូន ។

ទេវិទ្ធៈ	មីង គុកវត្តប្រធាតុនេះគុកអីគេ?

ឹម ៈ	គុកដាក់ប្រជាជនយើងរាល់ដងហ្នឹង អ្នកណាមានរឿងអីនៅហ្នឹងហើយ ។

ទេវិទ្ធៈ	ជាគុកស្រុកមែន?

ទឹម : គុកស្រុក ។

ទេវិទ្ធ: ចុះគុកតំបន់គេនៅណាវិញ?

ទឹម : គុកតំបន់នៅណាទេ នៅលើនោះ ។

ទេវិទ្ធ: នៅកន្លែងណា?

ទឹម : នៅកន្លែងតាកែវភ្នំពេញនោះ ។

ទេវិទ្ធ: នៅភ្នំពេញ?

ទឹម : នៅកន្លែងទួលស្លែងនោះ ។

ទេវិទ្ធ: ក្រៅពីគុកហ្នឹងមានគុកផ្សេងទេ ដែលគេចាប់ទៅ ក្រៅពីវត្តប្រធាតុហ្នឹង?

ទឹម : ក្រៅពីវត្តប្រធាតុហ្នឹង កាលជំនាន់ ប៉ុល ពត មានវត្តស្លែងហើយមានតែគេដាក់តាមវត្ត ហ្នឹង ឃើញតែគេចងតាមវត្តអាណោងអាណោងហ្នឹង មានអារឿងទីធ្លាគុកហ្នឹង អត់មាន ដាក់ ជិតហ្នឹងមួយដើម្បីកុំឲ្យប្រជាជនទៅជិតហ្នឹង ហើយអាណាទៅជិតក៏មិនបានដែរគុក នោះ អ្នកណាទៅជិតទៅយកការណ៍ហ្នឹងគេវ៉ៃយើងចោល កាលជំនាន់ ប៉ុល ពត ខ្ញុំបាន មកនៅហ្នឹង បានគេបានស្រាវជ្រាវឪពុកខ្ញុំធ្វើទាហាន ឪពុកខ្ញុំធ្វើប៉ូលីសណា៎ ពីសង្គមចាស់ អ្នកធ្វើជាមួយឪពុកខ្ញុំសុទ្ធតែប៉ូលីសទាំងអស់ ហើយដល់ជំនាន់ ប៉ុល ពត ចេះតែលាក់បាំង ជិតៗអ្នកស្រុកអ្នលភូមិអត់ដឹងថាឪពុកខ្ញុំធ្វើប៉ូលីស ឪពុកខ្ញុំនៅខេត្តកំពតនោះ ហើយអ្នក ស្រុក នោះអត់ដឹងណា៎ ឪពុកខ្ញុំប៉ូលីសចំ ។

ទេវិទ្ធ: បើសិនជាដឹងប្រហែលជា?

ទឹម : បើដឹងអស់មួយពូជបាត់ទៅហើយ មានខ្មែរប៉ូលីសស្មានតែពួក ប៉ុល ពត គេទុកយើងនៅ ដល់ហើយគេតាមដានបន្តិចៗក៏គេអត់ដឹងដែរ ឪពុកខ្ញុំនៅស្រុករពេង ហើយម៉ែខ្ញុំនេះនៅ ស្រុកលិចភ្នំនេះគេម៉េចហ្នឹងដឹង បើមនុស្សអាសេសអាសាសមកពីណាមក គេអត់តាមដាន យើងដឹងណា ។

ទេវិទ្ធ: ចុះមីង តាទិត ហ្នឹងត្រកូលគាត់ឈ្មោះអី?

ទឹម : មិនបានចាំទេ ។

ទេវិទ្ធ: អត់មានបានចាំត្រកូលគាត់ទេ?

ទឹម : មិនបានចាំទេ គ្រាន់តែមុខ តាទិត មិនដែលហ៊ានមើលផង ។

ទេវិទ្ធ: ប្រពន្ធគាត់ឈ្មោះអីគេ?

ទឹម : ប្រពន្ធគាត់ឈ្មោះ មីងកេន បើមីងកេន ហ្នឹងគ្រាន់ហ៊ានមើលខ្លះ បើ តាទិត តាគុំ ហ្នឹងមិន

ដែលហ៊ានមើលទេ ។

ទេវិទ្ធៈ គាទិត ហើយ គាគុំ ហ្នឹងបងប្អូនគ្នាមែន?

ទីម ៖ គាទិត ហ្នឹងគាត់គណៈស្រុកនៅហ្នឹងទាំងអស់ ។

ទេវិទ្ធៈ គាត់បងប្អូនគ្នាមែនបានជាឈ្មោះស្រដៀងគ្នា?

ទីម ៖ គាត់អ្នកស្រុកជាមួយគ្នាហ្នឹង ដល់ពេលអញ្ចឹងឈ្មោះដូនគ្នា ។

ទេវិទ្ធៈ ប្រពន្ធឈ្មោះ កេន?

ទីម ៖ ឈ្មោះ កេន ។

ទេវិទ្ធៈ ចុះ គាទិត ហ្នឹងគាត់គណៈស្រុក ហើយប្រពន្ធរបស់គាត់ធ្វើអីវិញ?

ទីម ៖ ប្រពន្ធធ្វើពេទ្យ ។

ទេវិទ្ធៈ អញ្ចឹងមីងធ្វើការពេទ្យជាមួយគាត់មែន?

ទីម ៖ ធ្វើពេទ្យដូចថាគាត់នៅវត្តតាអង្គនេះ ហើយខ្ញុំនៅវត្តផ្សេងអញ្ចឹងណា៎ វាមានពីរសាខា ហើយពេទ្យហ្នឹងគាត់ចិត្តល្អទេ យាយកេន ហ្នឹង បើខ្ញុំនៅជាមួយ យាយរឿន ហ្នឹងបានចិត្តអាក្រក់ ហើយដល់ពេល យាយរឿន ហ្នឹងខ្ញុំទៅជួបនៅភ្នំខាងលើងាប់ដូចគ្នាអញ្ចឹង សាងអំពើរអាក្រក់ដល់ពេលជួបគ្នាងាប់ទៅអញ្ចឹង តែមិនងាប់ឬមិនងាប់ ប៉ុន្តែគាត់គ្មានកូនហើយខ្ញុំមានកូន ។

ទេវិទ្ធៈ មីងមានស្គាល់ត្រកូលប្រពន្ធ គាទិត ហ្នឹងទេ?

ទីម ៖ អត់ស្គាល់ទេ ។

ទេវិទ្ធៈ គាត់កូនប៉ុន្មាននាក់ដែរ?

ទីម ៖ គាត់កូន៣នាក់ដែរហ្នឹង ។

ទេវិទ្ធៈ ប្រុសប៉ុន្មាន ហើយស្រីប៉ុន្មាន?

ទីម ៖ កូនស្រី១ កូនប្រុស២នាក់ ។

ទេវិទ្ធៈ មីងមានស្គាល់ឈ្មោះកូនហ្នឹងទេ?

ទីម ៖ ភ្លេចអស់ហើយ ស្គាល់តែ គេន មួយហ្នឹង ។

ទេវិទ្ធៈ ចុះមីងអត់ដែលបានជួបគាត់ទៀតទេ?

ទីម ៖ មិនដែលហ៊ានទៅជួបទេ ហើយឥលូវក៏មិនជួបដែរ គេនៅធំទៀតយើងម៉េចហ្នឹងហ៊ានជួបគេ ។

ទេវិទ្ធៈ គេធ្វើធំ?

ទឹម ៖ កាលធំកាលជំនាន់ ប៉ុល ពត អត់ហ៊ានមើលផង ហើយឥលូវក៏មិនដែលឃើញដែរ តែពួថា នៅវត្តភ្នំ ហើយពួគេថានៅធ្វើធំដដែល ។

ទេវិទ្ធៈ ធ្វើធំហើយធ្វើធំទៀត?

ទឹម ៖ ហ្នឹងអើយ ពីរជំនាន់ហើយនៅតែធ្វើធំ ។

ទេវិទ្ធៈ មីងរៀននៅណាដែរមីង គេឲ្យធ្វើពេទ្យហ្នុង?

ទឹម ៖ គ្មានរៀនគ្មានស្អីទេ ជំនាន់ប៉ុល ពត បើយើងធ្វើកើតក៏កើតបើយើងធ្វើមិនកើតគេរកតែវ៉ៃយើងចោលហ្នឹង ។

ទេវិទ្ធៈ ចុះមីងលែងបន្តវិជ្ជាជីវៈពេទ្យទៀតហើយ?

ទឹម ៖ អត់ទេ ឥលូវហ្នឹងបើយកក្បួនមានតែយកក្បួនលក់ថ្នាំពេទ្យ ក្បួនលក់ថ្នាំពេទ្យមានបងប្អូនឲ្យលក់តិចតួច ឥលូវដល់យើងអត់មានសញ្ញាប័ត្រហ្នឹងក្រែងរដ្ឋអំណាចធ្វើទុកទោស ។

ទេវិទ្ធៈ មីងមានសល់ឯកសារអីទេ ដូចថាមានសល់រូបថតកាលពេលមីងនៅរៀន?

ទឹម ៖ កាលពេលរៀនហ្នឹង?

ទេវិទ្ធៈ បាទ!

ទឹម ៖ គ្មានទេ មានបានសល់អីទុកនៅក្នុងខ្លួននោះទេ ។

ទេវិទ្ធៈ ចុះសៀវភៅពេទ្យសៀវភៅអីមាននៅសល់ទេ?

ទឹម ៖ មានទៅរៀនក្បួនពេទ្យណាទេ តាមពិតមានក្បួនពេទ្យណាឲ្យរៀនទេ ។

ទេវិទ្ធៈ អញ្ចឹងអត់មានអីនៅសេសសល់កាលពីសម័យមុនទេ?

ទឹម ៖ អត់មានទេ ។

ទេវិទ្ធៈ អត់មានក្បួនមានអីទេ?

ទឹម ៖ មានតែក្បួនរត់ហ្នឹង និយាយប្រាប់បងប្អូនយំសោកប្រាប់បងប្អូនតែប៉ុណ្ណឹង ។ និយាយអញ្ចឹង កាលខ្ញុំមកពីលើមកពីខេត្តកំពង់ឆ្នាំង ឡានអ្នកធ្វើការមកសួរខ្ញុំ គាត់និយាយទឹកភ្នែកហើយខ្ញុំក៏យំដែរ សួរខ្ញុំច្រើនពេកខ្ញុំយំ ចុះបើមិនទាន់បាត់ពិបាកផងគាត់មកសួរ ហើយខ្ញុំថាពូអើយកុំសួរខ្ញុំច្រើនពេកប្រវត្តិខ្ញុំវេទនាណាស់ ហើយខ្ញុំជៀសស្លាប់មិនរួចទេ នឹកឃើញតែដល់ផ្ទះដង្ហើមហេតៗ មិនដឹងឆាប់ត្រឹមម៉ាន មិនដែលស្គាល់បាយទឹកទេ ដល់ពេលមកហ្នឹងគេឲ្យបាយហូប ។

ទេវិទ្ធៈ អញ្ចឹងមីងខ្ញុំសូមអរគុណមីងច្រើនដែលបានជួយចែករំលែក ។

ទឹម ៖ ហើយមានយកមកផ្សាយអញ្ចឹងដែរ?

ទេវិទ្ធៈ	អត់ទេមីង ពួកខ្ញុំគ្រាន់តែយកទៅចងក្រងជាឯកសារ ហើយមីងអនុញ្ញាតឲ្យពួកខ្ញុំសរសេរជាអត្ថបទក៏បានដែរមីង សរសេររឿងបានទេមីង ។

ទឹម :	ល្មមជារឿងមួយទុកដែរហ្នឹង បើថាម៉េចៗយកមកឲ្យកូនមួយទុកគ្រាន់តកូនបន្តិចដែរ ។

ទេវិទ្ធៈ	អញ្ចឹងមីង?

ទឹម :	ហើយរាល់ថ្ងៃហ្នឹងចង់បណ្តុះកូនឲ្យរៀនចេះដឹង កូនរៀនអត់កើតសោះ ថាស្តាយរាល់ថ្ងៃនឹកឃើញខ្លួនឯងល្ងង់ណាអូន ចង់ឲ្យកូនរៀនតែកូនរៀនអត់កើត ។

ទេវិទ្ធៈ	អញ្ចឹងមីងមានដែលនិយាយរឿងប្រាប់កូនទេ?

ទឹម :	និយាយ ។

ទេវិទ្ធៈ	ហើយពួកគាត់ជឿទេ?

ទឹម :	កូនខ្ញុំជឿ ហើយដល់ពេលឥលូវគេថាម៉ែចិញ្ចឹមខ្ញុំទាំងវេទនា ខ្ញុំសងគុណម៉ែឯង អាហ្នឹងគេនិយាយរាល់ថ្ងៃហ្នឹងតែ១ម៉ឺនហ្នឹងរួចគ្នាហើយ ហើយខ្ញុំថា១០ម៉ឺនក៏អត់រួចគ្នាដែរ ជីវិតកូនឯងរាល់ថ្ងៃបើម៉ែថាឲ្យរួចបានរួច តែបើម៉ែថាមិនរួចគឺមិនរួចហើយ ។

ទេវិទ្ធៈ	អញ្ចឹងកាលដែលមីងឲ្យកូនរៀនពីរបបហ្នឹងមានន័យថាឲ្យដឹងពីការខុសត្រូវ រឿងទាក់ទងពីរបបហ្នឹងថាវាសំខាន់យ៉ាងម៉េច រៀនដូចថាដឹងរបបហ្នឹងវាម៉េចអញ្ចឹងណា៎ ដូចថាថ្ងៃក្រោយកុំឲ្យវាមានរបបហ្នឹងទៀត ។

ទឹម :	ហ្នឹងអើយ ឲ្យកូនហ្នឹងវាចេះដឹងហ្នឹងណា៎ ហើយឲ្យកូនគស្ញូ ឲ្យដឹងថាម៉ែហ្នឹងល្វិតល្វន់វេទនាយ៉ាងហ្នឹង ចង់ឲ្យកូនឃើញគេអ្នកធ្វើការរាល់ថ្ងៃ ហើយចង់បណ្តុះកូនឲ្យចេះមានមុខអីមួយរាល់ថ្ងៃស្រលាញ់កូនណាស់ ចង់ឲ្យកូនរៀនម៉េចក៏កូនរៀនអត់កើត ហើយទោះបីក្រម៉េចក៏ចង់ឲ្យកូនរៀនដែរ ហើយបើម៉េចជួយចងក្រងមួយច្បាប់ទុកឲ្យកូនខ្ញុំមើលផង ហើយខ្ញុំថាកូនឯងមុនហ្នឹងម៉ែស្លាប់ម៉ែថតសម្លេងទុកឲ្យកូនឯងស្តាប់ ថាម៉ែហ្នឹងវេទនាប៉ុណ្ណា កូនឯងស្តាប់មើល អត់មានថ្ងៃសង្ឃឹមរស់បន្តិចសោះ គេចង់ឲ្យមាសប៉ុន្នានក៏អត់រើសយកដែរ ព្រោះអីឲ្យខ្ញុំយកធ្វើអីបើខ្ញុំមានតែថ្ងៃផាប់ហ្នឹង ឲ្យមាសនៅលើភ្នំមិនដឹងយកទៅណាអស់ទេ វាសង្ឃឹមខ្លួនជីវិតអត់មានរស់ទេ ។

ទេវិទ្ធៈ	អត់អីទេមីងចាំខ្ញុំសរសេរហើយយកមកជូនមីង ។

ទឹម :	ចា៎! ម៉េចៗចាំយកឲ្យខ្ញុំមួយផង ។

ទេវិទ្ធៈ	បាទ! អញ្ចឹងអរគុណមីងច្រើនហើយ ។

ទឹម :	ចា៎!

«ចប់»